# កម្រងសេចក្តីណែនាំ
# សម្រាប់បុគ្គលរាយការណ៍ប្រើប្រាស់
# ដើម្បីអនុវត្តច្បាប់ស្តីពីការប្រឆាំង
# ការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម

អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា
២០២៣

# កម្រងសេចក្តីណែនាំ
# សម្រាប់បុគ្គលរាយការណ៍ប្រើប្រាស់
# ដើម្បីអនុវត្តច្បាប់ស្តីពីការប្រឆាំង
# ការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម

# មាតិកា


១. សេចក្តីណែនាំ ស្តីពី ការផ្ទេរប្រាក់ និងការផ្ទេរតាមប្រព័ន្ធអេឡិចត្រូនិក.......................................១

២. សេចក្តីណែនាំ ស្តីពី ទំនាក់ទំនងធនាគារឆ្លើយឆ្លង និងទំនាក់ទំនងប្រហាក់ប្រហែល........................៦

៣. សេចក្តីណែនាំ ស្តីពី ការត្រួតពិនិត្យផ្ទៃក្នុងសម្រាប់បុគ្គលរាយការណ៍.......................................៩

៤. សេចក្តីណែនាំ ស្តីពី វិធានការយកចិត្តទុកដាក់ស្គាល់អតិថិជន.......................................១៧

៥. សេចក្តីណែនាំ ស្តីពី ការកំណត់ចំនួនទឹកប្រាក់ក្នុងការអនុវត្តវិធានការយកចិត្តទុកដាក់ស្គាល់អតិថិជន សម្រាប់កាស៊ីណូ និងគ្រឹះស្ថានល្បែងស៊ីសងផ្សេងៗ.......................................២៩

៦. សេចក្តីណែនាំ ស្តីពី ការត្រួតពិនិត្យផ្អែកលើហានិភ័យ.......................................៣០

# សេចក្តីណែនាំ
# ស្តីពី
# ការផ្ទេរប្រាក់ និងការផ្ទេរតាមប្រព័ន្ធអេឡិចត្រូនិក

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា**

លេខ...០១២.០២២.០១០ ស.ក.ណ.ស

# សេចក្តីណែនាំ
# ស្តីពី
# ការផ្ទេរប្រាក់ និងការផ្ទេរតាមប្រព័ន្ធអេឡិចត្រូនិក

អនុលោមតាមច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម បានប្រកាសឱ្យប្រើដោយព្រះរាជក្រម លេខ នស/រកម/០៦២០/០២១ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២០ អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា បានចេញសេចក្តីណែនាំស្តីពីការផ្ទេរប្រាក់ និងការផ្ទេរតាមប្រព័ន្ធអេឡិចត្រូនិក។ សេចក្តីណែនាំនេះក៏ត្រូវអនុវត្តផងដែរចំពោះភ្នាក់ងារដែលពាក់ព័ន្ធ។

## ១. វិសាលភាព

សេចក្តីណែនាំនេះត្រូវអនុវត្តចំពោះបុគ្គលរាយការណ៍ ដូចមានចែងក្នុងមាត្រា៤ នៃច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម នៅពេលបុគ្គលរាយការណ៍ទាំងនោះចូលរួមក្នុងប្រតិបត្តិការផ្ទេរប្រាក់ និងការផ្ទេរតាមប្រព័ន្ធអេឡិចត្រូនិក។

## ២. និយមន័យ

**ការផ្ទេរប្រាក់តាមប្រព័ន្ធអេឡិចត្រូនិក** គឺជាការផ្ទេរប្រាក់ដែលអ្នកផ្តើមប្រតិបត្តិការធ្វើឡើងដោយប្រើប្រាស់មធ្យោបាយអេឡិចត្រូនិករវាងគ្រឹះស្ថានហិរញ្ញវត្ថុ ក្នុងគោលបំណងផ្តល់មូលនិធិដល់អ្នកទទួលផល ទោះបីជាអ្នកផ្តើមប្រតិបត្តិការ និងអ្នកទទួលផលជាមនុស្សតែម្នាក់ក៏ដោយ។

**អ្នកផ្តើមប្រតិបត្តិការ** គឺជាម្ចាស់គណនីដែលបានធ្វើប្រតិបត្តិការផ្ទេរប្រាក់តាមអេឡិចត្រូនិក ពីគណនីរបស់ខ្លួន ឬក្នុងករណីគ្មានគណនី រូបវន្តបុគ្គល ឬនីតិបុគ្គលដែលបានបញ្ជាទៅគ្រឹះស្ថានហិរញ្ញវត្ថុឱ្យធ្វើប្រតិបត្តិការផ្ទេរប្រាក់តាមអេឡិចត្រូនិក។

**អ្នកទទួលផល** គឺជារូបវន្តបុគ្គល ឬនីតិបុគ្គល ឬកិច្ចសម្របសម្រួលផ្លូវច្បាប់ ដែលអ្នកផ្តើមប្រតិបត្តិការបានកំណត់ថាជាអ្នកទទួលបានប្រតិបត្តិការផ្ទេរប្រាក់តាមអេឡិចត្រូនិក។

**ការផ្ទេរប្រាក់ឆ្លងដែនតាមប្រព័ន្ធអេឡិចត្រូនិក** គឺជាការផ្ទេរប្រាក់តាមប្រព័ន្ធអេឡិចត្រូនិកណាមួយដែលត្រូវបានធ្វើឡើងដោយគ្រឹះស្ថានហិរញ្ញវត្ថុជាអ្នកផ្តើមប្រតិបត្តិការ និងគ្រឹះស្ថានហិរញ្ញវត្ថុជាអ្នកទទួលផល មានទីតាំងនៅប្រទេសផ្សេងគ្នា។



ប្រអប់សំបុត្រលេខ ៦៧ ឡូត៍លេខ ២២-២៤ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ www.nbc.org.kh/cafiu cafiu_info@nbc.org.kh

**ការផ្ទេរប្រាក់ក្នុងស្រុកតាមប្រព័ន្ធអេឡិចត្រូនិក** គឺជាប្រតិបត្តិការផ្ទេរប្រាក់ណាមួយតាមប្រព័ន្ធអេឡិចត្រូនិក ដែលត្រូវបានធ្វើឡើងដោយគ្រឹះស្ថានហិរញ្ញវត្ថុជាអ្នកផ្ដើមប្រតិបត្តិការ និងគ្រឹះស្ថានហិរញ្ញវត្ថុជាអ្នកទទួលផល មានទីតាំងនៅក្នុងប្រទេសតែមួយ។

**សេវាផ្ទេរប្រាក់ឬឧបករណ៍មានតម្លៃ** គឺជាសេវាហិរញ្ញវត្ថុដែលពាក់ព័ន្ធនឹងការទទួលបានសាច់ប្រាក់ មូលប្បទានបត្រ ឧបករណ៍រូបិយវត្ថុផ្សេងទៀត ឬឧបករណ៍រក្សាតម្លៃផ្សេងៗ និងការទូទាត់ជាសាច់ប្រាក់ ឬជាទម្រង់ផ្សេងទៀតដែលមានតម្លៃសរុបស្មើទំហំសាច់ប្រាក់មួយដល់អ្នកទទួលផល តាមរយៈមធ្យោបាយទំនាក់ទំនង ការបញ្ជូនសារ ការផ្ទេរ ឬតាមរយៈបណ្ដាញផាត់ទាត់ ដែលគ្រឹះស្ថានផ្ដល់សេវាផ្ទេរប្រាក់ ឬឧបករណ៍មានតម្លៃ ដាក់ឱ្យប្រើប្រាស់។

**ភ្នាក់ងារ** គឺជារូបវន្តបុគ្គល ឬនីតិបុគ្គល ដែលផ្ដល់សេវាផ្ទេរប្រាក់ ឬឧបករណ៍មានតម្លៃ ក្នុងនាមគ្រឹះស្ថានផ្ដល់សេវាផ្ទេរប្រាក់ ឬឧបករណ៍មានតម្លៃ។

## ៣. ការផ្ទេរប្រាក់តាមប្រព័ន្ធអេឡិចត្រូនិក៖ ការផ្ដើមប្រតិបត្តិការ

៣.១. បុគ្គលរាយការណ៍ដែលធ្វើ ឬចូលរួមក្នុងប្រតិបត្តិការផ្ទេរប្រាក់ឆ្លងដែនតាមប្រព័ន្ធអេឡិចត្រូនិក ដែលមានទឹកប្រាក់ស្មើ ឬលើសពី ៤.០០០.០០០ (បួនលាន) រៀល ឬរូបិយប័ណ្ណមានតម្លៃស្មើ ត្រូវបញ្ចូល និងផ្ទៀងផ្ទាត់ព័ត៌មានរបស់អ្នកផ្ដើមប្រតិបត្តិការផ្ទេរប្រាក់ឆ្លងដែនតាមប្រព័ន្ធអេឡិចត្រូនិក យ៉ាងហោចណាស់៖

ក- ឈ្មោះពេញរបស់អ្នកផ្ដើមប្រតិបត្តិការ

ខ- លេខគណនីរបស់អ្នកផ្ដើមប្រតិបត្តិការ ឬក្នុងករណីគ្មានលេខគណនី ត្រូវមានលេខយោងប្រតិបត្តិការ ដើម្បីអាចតាមដានប្រតិបត្តិការ

គ- អាសយដ្ឋាន ឬលេខសម្គាល់អត្តសញ្ញាណអតិថិជន ឬលេខអត្តសញ្ញាណ ដែលចេញផ្សាយដោយអាជ្ញាធរមានសមត្ថកិច្ច ឬកាលបរិច្ឆេទនិងទីកន្លែងកំណើតរបស់អ្នកផ្ដើមប្រតិបត្តិការ និង

ឃ- គោលបំណងនៃការធ្វើប្រតិបត្តិការ។

៣.២. បុគ្គលរាយការណ៍ដែលធ្វើ ឬចូលរួមក្នុងប្រតិបត្តិការផ្ទេរប្រាក់ឆ្លងដែនតាមប្រព័ន្ធអេឡិចត្រូនិក ដែលមានចំនួនទឹកប្រាក់ស្មើ ឬលើសពី ៤.០០០.០០០ (បួនលាន) រៀល ឬរូបិយប័ណ្ណមានតម្លៃស្មើ ត្រូវបញ្ចូល និងផ្ទៀងផ្ទាត់ព័ត៌មានអ្នកទទួលផល នៅក្នុងប្រតិបត្តិការផ្ទេរប្រាក់ឆ្លងដែនតាមប្រព័ន្ធអេឡិចត្រូនិកនោះ ដូចខាងក្រោម៖

ក- ឈ្មោះពេញរបស់អ្នកទទួលផល

ខ- លេខគណនីរបស់អ្នកទទួលផល ឬក្នុងករណីគ្មានលេខគណនី ត្រូវមានលេខយោងប្រតិបត្តិការ ដើម្បីអាចតាមដានប្រតិបត្តិការ។

៣.៣. នៅពេលមានអ្នកផ្ដើមប្រតិបត្តិការតែម្នាក់ផ្ទេរប្រាក់តាមប្រព័ន្ធអេឡិចត្រូនិកច្រើន ដែលមានទឹកប្រាក់សរុបស្មើ ឬលើសពី ៤.០០០.០០០ (បួនលាន) រៀល ឬរូបិយប័ណ្ណមានតម្លៃស្មើ នៅក្នុងរយៈពេលមួយថ្ងៃ បុគ្គលរាយការណ៍ត្រូវរួមបញ្ចូលក្នុងសំណុំតែមួយ សម្រាប់ផ្ទេរទៅអ្នកទទួលផលមួយ ឬច្រើននាក់។ បុគ្គលរាយការណ៍ត្រូវបញ្ចូលព័ត៌មានចាំបាច់

ទាំងអស់របស់អ្នកផ្ដើមប្រតិបត្តិការ និងអ្នកទទួលផលឱ្យបានត្រឹមត្រូវនិងពេញលេញទៅក្នុងសំណុំប្រតិបត្តិការនោះ ដូចបានកំណត់នៅក្នុងចំណុច ៣.១ និង៣.២ នៃសេចក្ដីណែនាំនេះ និងផ្ទៀងផ្ទាត់ព័ត៌មានទាំងនោះឱ្យបានត្រឹមត្រូវ ដើម្បីមានកំណត់ត្រាព័ត៌មានរបស់អ្នកទទួលផលនៅក្រៅប្រទេស។

៣.៤. ប្រតិបត្តិការផ្ទេរប្រាក់ឆ្លងដែនតាមប្រព័ន្ធអេឡិចត្រូនិក ដែលមានចំនួនទឹកប្រាក់តិចជាង ៤.០០០.០០០ (បួនលាន) រៀល ឬរូបិយប័ណ្ណមានតម្លៃស្មើ ត្រូវមានព័ត៌មានដូចបានកំណត់នៅក្នុងចំណុច ៣.១ (ក) (ខ) និង(ឃ) និងចំណុច ៣.២ (ក) និង(ខ) នៃសេចក្ដីណែនាំនេះ។

៣.៥. បុគ្គលរាយការណ៍មិនចាំបាច់ផ្ទៀងផ្ទាត់ព័ត៌មានដែលភ្ជាប់ជាមួយប្រតិបត្តិការផ្ទេរប្រាក់ឆ្លងដែនតាមប្រព័ន្ធអេឡិចត្រូនិក ដូចបានកំណត់នៅក្នុងចំណុច ៣.៤ នៃសេចក្ដីណែនាំនេះ លើកលែងតែមានការសង្ស័យអំពីការសម្អាតប្រាក់ឬហិរញ្ញប្បទានភេរវកម្ម ឬប្រតិបត្តិការនោះអាចជាប់ពាក់ព័ន្ធនឹងសំអាងនៃបទល្មើស ឬសកម្មភាពសម្អាតប្រាក់ឬហិរញ្ញប្បទានភេរវកម្ម ដែលក្នុងករណីនេះ បុគ្គលរាយការណ៍ត្រូវផ្ទៀងផ្ទាត់ព័ត៌មានលម្អិតរបស់អតិថិជនឱ្យបានពេញលេញនិងឆាប់រហ័សតាមតែអាចធ្វើទៅបាន។

៣.៦. ចំពោះការផ្ទេរប្រាក់ក្នុងស្រុកតាមប្រព័ន្ធអេឡិចត្រូនិក បុគ្គលរាយការណ៍ត្រូវភ្ជាប់ព័ត៌មានរបស់អ្នកផ្ដើមប្រតិបត្តិការ ដូចបានកំណត់នៅក្នុងចំណុច ៣.១ និងព័ត៌មានរបស់អ្នកទទួលផល ដូចបានកំណត់នៅក្នុងចំណុច ៣.២ នៃសេចក្ដីណែនាំនេះ ជាមួយនឹងប្រតិបត្តិការផ្ទេរប្រាក់ លើកលែងតែព័ត៌មាននេះអាចបញ្ជូនទៅគ្រឹះស្ថានហិរញ្ញវត្ថុរបស់អ្នកទទួលផលតាមមធ្យោបាយផ្សេងទៀតបាន។ ក្នុងករណីបញ្ជូនព័ត៌មានតាមមធ្យោបាយផ្សេង បុគ្គលរាយការណ៍ត្រូវបញ្ចូលតែលេខគណនី ឬលេខយោងប្រតិបត្តិការរបស់អ្នកផ្ដើមប្រតិបត្តិការ និងអ្នកទទួលផលជាមួយនឹងប្រតិបត្តិការផ្ទេរប្រាក់ទៅបុគ្គលរាយការណ៍របស់អ្នកទទួលផល។

៣.៧. នៅពេលព័ត៌មានរបស់អ្នកផ្ដើមប្រតិបត្តិការមិនត្រូវបានភ្ជាប់ជាមួយនឹងប្រតិបត្តិការផ្ទេរប្រាក់ក្នុងស្រុកតាមប្រព័ន្ធអេឡិចត្រូនិកឱ្យបានពេញលេញ បុគ្គលរាយការណ៍របស់អ្នកផ្ដើមប្រតិបត្តិការត្រូវផ្ដល់ព័ត៌មានបន្ថែមនៅក្នុងរយៈពេល ៣ (បី) ថ្ងៃ ធ្វើការយ៉ាងយូរ បន្ទាប់ពីទទួលបានការស្នើសុំរបស់គ្រឹះស្ថានហិរញ្ញវត្ថុរបស់អ្នកទទួលផល ឬអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា។

៣.៨. បុគ្គលរាយការណ៍ត្រូវរក្សាទុករាល់ព័ត៌មានរបស់អ្នកផ្ដើមប្រតិបត្តិការ និងអ្នកទទួលផល ស្របតាមមាត្រា១១ នៃច្បាប់ស្ដីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម។

៣.៩. បុគ្គលរាយការណ៍មិនត្រូវធ្វើប្រតិបត្តិការផ្ទេរប្រាក់តាមប្រព័ន្ធអេឡិចត្រូនិក ប្រសិនអ្នកផ្ដើមប្រតិបត្តិការមិនអាចអនុវត្តតាមការតម្រូវនៅក្នុងចំណុច ៣.១ នៃសេចក្ដីណែនាំនេះ។

## ៤. ការផ្ទេរតាមប្រព័ន្ធអេឡិចត្រូនិក៖ អន្តរការីយកម្ម

៤.១. បុគ្គលរាយការណ៍ធ្វើជាអន្តរការីក្នុងការផ្ទេរប្រាក់តាមប្រព័ន្ធអេឡិចត្រូនិក ដែលគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងទៀតធ្វើប្រតិបត្តិការជំនួសឱ្យអ្នកផ្ដើមប្រតិបត្តិការ ត្រូវធានាថាព័ត៌មានទាំងអស់របស់អ្នកផ្ដើមប្រតិបត្តិការ និងអ្នកទទួលផលត្រូវមានភ្ជាប់ជាមួយប្រតិបត្តិការផ្ទេរប្រាក់នោះ។

៤.២. នៅពេលមានបញ្ហាបច្ចេកទេសដែលមិនអាចបញ្ជូនព័ត៌មានរបស់អ្នកផ្ដើមប្រតិបត្តិការ ឬអ្នកទទួលផល ក្នុងការផ្ទេរប្រាក់ពីប្រព័ន្ធអេឡិចត្រូនិកឆ្លងដែនទៅប្រព័ន្ធអេឡិចត្រូនិកក្នុងស្រុក បុគ្គលរាយការណ៍ ដែលជាអន្តរការីត្រូវរក្សាទុកកំណត់ត្រានៃព័ត៌មានដែលទទួលបានពីគ្រឹះស្ថានហិរញ្ញវត្ថុជាអ្នកផ្ដើមប្រតិបត្តិការ ឬពីគ្រឹះស្ថានហិរញ្ញវត្ថុជាអន្តរការីផ្សេងទៀត យ៉ាងហោចណាស់ ៥ (ប្រាំ) ឆ្នាំ ចាប់ពីកាលបរិច្ឆេទនៃប្រតិបត្តិការ។

៤.៣. បុគ្គលរាយការណ៍ដែលជាអន្តរការីក្នុងការផ្ទេរប្រាក់តាមប្រព័ន្ធអេឡិចត្រូនិក ត្រូវមាននីតិវិធីច្បាស់លាស់ស្របតាមដំណាក់កាលនៃការផ្ទេរប្រាក់ដោយស្វ័យប្រវត្តិតាមអេឡិចត្រូនិក (straight-through processing) និងអាចកំណត់បានពីប្រតិបត្តិការផ្ទេរប្រាក់ឆ្លងដែនតាមប្រព័ន្ធអេឡិចត្រូនិក ដែលពុំមានព័ត៌មានអ្នកផ្ដើមប្រតិបត្តិការ និងអ្នកទទួលផលដូចបានកំណត់នៅក្នុងចំណុច ៣.១ និង៣.២ នៃសេចក្ដីណែនាំនេះ។

៤.៤. បុគ្គលរាយការណ៍ដែលជាអន្តរការីក្នុងការផ្ទេរប្រាក់តាមប្រព័ន្ធអេឡិចត្រូនិក ត្រូវមានគោលនយោបាយ និងនីតិវិធីផ្អែកលើហានិភ័យ ដើម្បីកំណត់ថា៖

ក- នៅពេលត្រូវធ្វើ បដិសេធ ឬព្យួរ ប្រតិបត្តិការផ្ទេរប្រាក់តាមប្រព័ន្ធអេឡិចត្រូនិកដែលពុំមានព័ត៌មានចាំបាច់អំពីអ្នកផ្ដើមប្រតិបត្តិការ ឬអ្នកទទួលផល និង

ខ- វិធានការឆ្លើយតបមានភាពសមស្រប ដូចជាការរឹតត្បិត ឬការបញ្ចប់ទំនាក់ទំនងអាជីវកម្ម ជាដើម។

## ៥. ការផ្ទេរតាមប្រព័ន្ធអេឡិចត្រូនិក៖ ការទទួលផល

៥.១. បុគ្គលរាយការណ៍ដែលផ្ដល់សេវាឱ្យអ្នកទទួលផលនៃការផ្ទេរប្រាក់តាមប្រព័ន្ធអេឡិចត្រូនិក ត្រូវមាននីតិវិធីតាមដានភ្លាមៗក្រោយបញ្ចប់ប្រតិបត្តិការ ឬតាមដានជាប្រចាំ ដែលអាចកំណត់ការផ្ទេរប្រាក់ឆ្លងដែនតាមប្រព័ន្ធអេឡិចត្រូនិកដែលពុំមានព័ត៌មានត្រឹមត្រូវនិងពេញលេញរបស់អ្នកផ្ដើមប្រតិបត្តិការ ឬអ្នកទទួលផល ដូចបានកំណត់នៅក្នុងចំណុច ៣.១ និង៣.២ នៃសេចក្ដីណែនាំនេះ។

៥.២. បុគ្គលរាយការណ៍ដែលទទួលការផ្ទេរប្រាក់ចូលតាមប្រព័ន្ធអេឡិចត្រូនិក ដែលមានទឹកប្រាក់ស្មើ ឬលើសពី ៤.០០០.០០០ (បួនលាន) រៀល ឬរូបិយប័ណ្ណមានតម្លៃស្មើ ត្រូវផ្ទៀងផ្ទាត់អត្តសញ្ញាណអ្នកទទួលផល ប្រសិនបើមិនទាន់មានការកំណត់និងផ្ទៀងផ្ទាត់អត្តសញ្ញាណ ស្របតាមកាតព្វកិច្ចនៃច្បាប់ស្ដីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ឬចំណុច ៣.១ និង៣.២ នៃសេចក្ដីណែនាំនេះ។ ព័ត៌មានរបស់អ្នកទទួលផលដែលទទួលបានពីការកំណត់ ឬការផ្ទៀងផ្ទាត់អត្តសញ្ញាណ ត្រូវរក្សាទុក ស្របតាមមាត្រា១១ នៃច្បាប់ស្ដីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម។

៥.៣. បុគ្គលរាយការណ៍ដែលធ្វើជាអ្នកទទួលផលនៃការផ្ទេរប្រាក់ចូលតាមប្រព័ន្ធអេឡិចត្រូនិក ត្រូវមានគោលនយោបាយ និងនីតិវិធីផ្អែកលើហានិភ័យ ដើម្បីកំណត់ថា៖

ក- នៅពេលត្រូវធ្វើ បដិសេធ ឬព្យួរ ប្រតិបត្តិការផ្ទេរប្រាក់តាមប្រព័ន្ធអេឡិចត្រូនិកដែលពុំមានព័ត៌មានអំពីអ្នកផ្ដើមប្រតិបត្តិការ ឬអ្នកទទួលផល និង

ខ- វិធានការឆ្លើយតបមានភាពសមស្រប ដូចជាការរឹតត្បិត ឬការបញ្ចប់ទំនាក់ទំនងអាជីវកម្ម ជាដើម។

## ៦. សេវាផ្ទេរប្រាក់ឬឧបករណ៍មានតម្លៃ

៦.១. បុគ្គលរាយការណ៍ដែលផ្តល់សេវា ឬធ្វើជាភ្នាក់ងារផ្ទេរប្រាក់ឬឧបករណ៍មានតម្លៃ ត្រូវអនុវត្តតាមការតម្រូវទាំងអស់នៃសេចក្តីណែនាំនេះ ទោះបីបុគ្គលរាយការណ៍ធ្វើប្រតិបត្តិការដោយផ្ទាល់ ឬតាមរយៈភ្នាក់ងាររបស់ពួកគេ នៅក្នុងប្រទេសណាក៏ដោយ ។

៦.២. បុគ្គលរាយការណ៍ដែលផ្តល់សេវាផ្ទេរប្រាក់ឬឧបករណ៍មានតម្លៃ ដែលត្រួតពិនិត្យទាំងផ្នែកផ្តើមនិងផ្នែកទទួលផលនៃប្រតិបត្តិការទាំងនោះ ត្រូវ ៖

ក- យកចិត្តទុកដាក់ប្រមូលព័ត៌មានទាំងអស់ ដែលទទួលបានពីផ្នែកផ្តើមនិងផ្នែកទទួលផល ដើម្បីកំណត់ពីប្រតិបត្តិការសង្ស័យ ដែលត្រូវរាយការណ៍ទៅអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា

ខ- រាយការណ៍ប្រតិបត្តិការសង្ស័យនៅប្រទេសណាមួយដែលពាក់ព័ន្ធនឹងប្រតិបត្តិការផ្ទេរ សេវាផ្ទេរប្រាក់ឬឧបករណ៍មានតម្លៃ និងផ្តល់ព័ត៌មានប្រតិបត្តិការដែលពាក់ព័ន្ធផ្សេងៗ ទៅអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា និង

គ- តាមដានសកម្មភាពរបស់ភ្នាក់ងារអំពីការងារប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម។

## ៧. ការដាក់ទណ្ឌកម្មហិរញ្ញវត្ថុតាមគោលដៅ

នៅក្នុងដំណើរការផ្ទេរតាមប្រព័ន្ធអេឡិចត្រូនិក បុគ្គលរាយការណ៍ត្រូវចាត់វិធានការបង្កក និងអនុវត្តការហាមឃាត់ក្នុងការធ្វើប្រតិបត្តិការជាមួយរូបវន្តបុគ្គល និងនីតិបុគ្គលដែលជាប់ឈ្មោះក្នុងបញ្ជីដូចការតម្រូវនានាដែលបានកំណត់នៅក្នុងអនុក្រឹត្យស្តីពីការបង្កកទ្រព្យសម្បត្តិរបស់ភេរវករ និងអង្គការនានា ដែលពាក់ព័ន្ធនឹងការទប់ស្កាត់ និងការបង្ក្រាបសកម្មភាពភេរវកម្ម និងការផ្តល់ហិរញ្ញប្បទានភេរវកម្ម រួមបញ្ចូលទាំងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខនៃអង្គការសហប្រជាជាតិ លេខ ១២៦៧ និង១៣៧៣ និងសេចក្តីសម្រេចបន្តបន្ទាប់ ។

## ៨. ទណ្ឌកម្ម

បុគ្គលរាយការណ៍ណាដែលមិនគោរពតាមសេចក្តីណែនាំនេះត្រូវទទួលរងទណ្ឌកម្ម ដូចមានចែងក្នុងមាត្រា៣៦ និងមាត្រា៣៧ នៃច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម។

ទទួលបានសេចក្តីណែនាំនេះគ្រប់បុគ្គលរាយការណ៍ត្រូវអនុវត្តតាមសេចក្តីណែនាំនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃអង្គារ ៩កើត ខែបុស្ស ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី១១ ខែមករា ឆ្នាំ២០២២

**អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា**

**ប្រធាន**

**សាយ សំអាត**

**ចម្លងជូន៖**

- ការិយាល័យទីស្តីការគណៈរដ្ឋមន្ត្រី
- គណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ
- ក្រុមប្រឹក្សាភិបាលអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា
- ឯកសារ-កាលប្បវត្តិ

# សេចក្តីណែនាំ

# ស្តីពី

# ចំណាត់ចំណងជាការឆ្លើយឆ្លង និងចំណាត់ចំណងប្រហាក់ប្រហែល

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា**

លេខ ៤១២.០២២.០០៩ ស.ក.ណ.ន

# សេចក្តីណែនាំ
# ស្តីពី
# ទំនាក់ទំនងធនាគារឆ្លើយឆ្លង និងទំនាក់ទំនងប្រហាក់ប្រហែល

អនុលោមតាមច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម បានប្រកាសឱ្យប្រើដោយព្រះរាជក្រម លេខ នស/រកម/០៦២០/០២១ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២០ អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា បានចេញសេចក្តីណែនាំស្តីពីទំនាក់ទំនងធនាគារឆ្លើយឆ្លង និងទំនាក់ទំនងប្រហាក់ប្រហែល។

## ១. វិសាលភាព

សេចក្តីណែនាំនេះត្រូវអនុវត្តចំពោះបុគ្គលរាយការណ៍ ដូចមានចែងក្នុងមាត្រា៤ នៃច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម នៅពេលបុគ្គលរាយការណ៍ទាំងនោះចូលរួមក្នុងសេវាទំនាក់ទំនងធនាគារឆ្លើយឆ្លង ឬទំនាក់ទំនងប្រហាក់ប្រហែលគ្នា។

## ២. និយមន័យ

**ប្រតិបត្តិការធនាគារឆ្លើយឆ្លង** គឺជាការផ្តល់សេវាធនាគារពីគ្រឹះស្ថានមួយហៅថា គ្រឹះស្ថានផ្តល់សេវា ទៅគ្រឹះស្ថានមួយទៀតហៅថា គ្រឹះស្ថានទទួលសេវា។

**ទំនាក់ទំនងប្រហាក់ប្រហែល** គឺជាទំនាក់ទំនងដែលកើតឡើងពីប្រតិបត្តិការពាក់ព័ន្ធនឹងមូលបត្រ ឬការផ្ទេរមូលនិធិសម្រាប់គ្រឹះស្ថានហិរញ្ញវត្ថុ ដែលកំពុងធ្វើប្រតិបត្តិការនៅក្រៅប្រទេសកម្ពុជា ក្នុងនាមខ្លួនឯងផ្ទាល់ ឬជំនួសឱ្យអតិថិជន។

**ធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុសំបក** គឺជាធនាគារ ឬគ្រឹះស្ថានហិរញ្ញវត្ថុ ដែលទទួលស្គាល់ជាផ្លូវការ ឬបង្កើតឡើង ឬចុះបញ្ជី ឬទទួលអាជ្ញាប័ណ្ណនៅក្នុងប្រទេស ឬយុត្តាធិការមួយ ដែលធនាគារ ឬគ្រឹះស្ថានហិរញ្ញវត្ថុនោះពុំមានរូបរាង ហើយមិនមែនជាសមាជិករបស់ក្រុមហិរញ្ញវត្ថុ ដែលស្ថិតក្រោមការត្រួតពិនិត្យគួបសរុប ជាធរមាន។

**គណនីសម្រាប់ការទូទាត់ឆ្លង** គឺជាគណនីធនាគារឆ្លើយឆ្លង ដែលភាគីទីបីអាចប្រើប្រាស់ដោយផ្ទាល់ ក្នុងការធ្វើប្រតិបត្តិការរបស់ខ្លួន។



ប្រអប់សំបុត្រលេខ ៦៧ ឡូត៍លេខ ២២-២៤ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ www.nbc.org.kh/cafiu cafiu_info@nbc.org.kh

## ៣. ប្រតិបត្តិការធនាគារឆ្លើយឆ្លង

៣.១. បុគ្គលរាយការណ៍ត្រូវចាត់វិធានការចាំបាច់ ដើម្បីជានាការជៀសផុតពីការគំរាមកំហែងនៃការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម តាមរយៈការប្រើប្រាស់គណនីឆ្លើយឆ្លង ដែលបានបើកជាមួយគ្រឹះស្ថានហិរញ្ញវត្ថុក្នុងស្រុក ឬអន្តរជាតិផ្សេងទៀត។ បុគ្គលរាយការណ៍ត្រូវបង្កើតគោលនយោបាយ និងនីតិវិធី សម្រាប់ប្រតិបត្តិការធនាគារឆ្លើយឆ្លង រួមទាំងវិធានការគ្រប់គ្រង និងកាត់បន្ថយហានិភ័យ។

៣.២. បុគ្គលរាយការណ៍ដែលមានទំនាក់ទំនងប្រតិបត្តិការធនាគារឆ្លើយឆ្លង ត្រូវប្រមូលនិងវាយតម្លៃព័ត៌មានអំពីគ្រឹះស្ថានទទួលសេវា មានជាអាទិ៍៖

ក- ក្រុមប្រឹក្សាភិបាល និងគណៈគ្រប់គ្រង

ខ- ប្រភេទ គោលបំណងសកម្មភាពអាជីវកម្ម និងផលិតផល ឬសេវា

គ- ប្រទេស ឬយុត្តាធិការ ដែលគ្រឹះស្ថានទទួលសេវាកំពុងប្រតិបត្តិការ

ឃ- កេរ្តិ៍ឈ្មោះដែលអាចកំណត់និងប្រមូលបានពីប្រភពព័ត៌មានសាធារណៈ ឬប្រភពព័ត៌មានផ្សេងទៀតដែលអាចមាន

ង- ច្បាប់ បទប្បញ្ញត្តិ និងការត្រួតពិនិត្យដែលរួមមានព័ត៌មានដែលបញ្ជាក់ថាគ្រឹះស្ថានទទួលសេវា កំពុងស្ថិតនៅក្រោមការស៊ើបអង្កេតការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ឬទទួលរងនូវវិធានការត្រួតពិនិត្យ ឬបញ្ញត្តិកម្មផ្សេងៗ

ច- វិធានការ និងការត្រួតពិនិត្យផ្ទៃក្នុងអំពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និង

ឆ- របាយការណ៍ប្រចាំឆ្នាំ។

៣.៣. បុគ្គលរាយការណ៍អាចបង្កើត ឬបន្តប្រតិបត្តិការធនាគារឆ្លើយឆ្លងបាន លុះត្រាតែមានការអនុម័តពីគណៈគ្រប់គ្រងជាន់ខ្ពស់ ដោយផ្អែកលើព័ត៌មាន ដូចខាងក្រោម៖

ក- ការវាយតម្លៃរាល់ព័ត៌មានទាំងអស់ដែលទទួលបាន បង្ហាញថាទំនាក់ទំនងនេះមានហានិភ័យសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មទាប និងអាចគ្រប់គ្រង ឬកាត់បន្ថយបាន និង

ខ- ភាគីទាំងពីរយល់ដឹងច្បាស់លាស់អំពីការទទួលខុសត្រូវរបស់ខ្លួន និងចងក្រងជាឯកសារលើការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម។

៣.៤. បុគ្គលរាយការណ៍ត្រូវបញ្ឈប់ទំនាក់ទំនង ឬមិនត្រូវបង្កើត ឬបន្តទំនាក់ទំនង ឬធ្វើប្រតិបត្តិការម្តងម្កាល ជាមួយធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុសំបកឡើយ។

៣.៥. បុគ្គលរាយការណ៍ត្រូវប្រាកដថា គ្រឹះស្ថានទទួលសេវាមិនអនុញ្ញាតឱ្យធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុសំបក ប្រើប្រាស់គណនីរបស់ខ្លួនឡើយ។

៣.៦. បុគ្គលរាយការណ៍ត្រូវអនុវត្តវិធានការបន្ថែមការយកចិត្តទុកដាក់ស្គាល់អតិថិជន ដូចបានកំណត់នៅក្នុងចំណុច ៤.៧ នៃសេចក្តីណែនាំស្តីពីវិធានការយកចិត្តទុកដាក់ស្គាល់អតិថិជន ចំពោះគ្រឹះស្ថានផ្តល់ ឬទទួលសេវា ដែលបានអនុញ្ញាតឱ្យអតិថិជនប្រើប្រាស់គណនីឆ្លើយឆ្លងដោយផ្ទាល់។ បុគ្គលរាយការណ៍ត្រូវអនុវត្តវិធានការយកចិត្តទុកដាក់ស្គាល់អតិថិជន ដូចមានចែងក្នុងចំណុច ៤.៥ នៃសេចក្តីណែនាំស្តីពីវិធានការយកចិត្តទុកដាក់ស្គាល់អតិថិជន ចំពោះអន្តរការីដែលជាអ្នកណែនាំការធ្វើអាជីវកម្ម។ លើសពីនេះ បុគ្គលរាយការណ៍ត្រូវធានាថា៖

ក- គ្រឹះស្ថានទទួលសេវាបានអនុវត្តការយកចិត្តទុកដាក់ស្គាល់អតិថិជន និងតាមដានជាប្រចាំរាល់ប្រតិបត្តិការអាជីវកម្មរបស់ខ្លួនចំពោះអតិថិជនដែលអនុញ្ញាតឱ្យប្រើប្រាស់ដោយផ្ទាល់លើគណនីសម្រាប់ទូទាត់ឆ្លង និង

ខ- គ្រឹះស្ថានទទួលសេវាអាចផ្តល់ព័ត៌មានអំពីការយកចិត្តទុកដាក់ស្គាល់អតិថិជនដល់ខ្លួន ឬអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា នៅពេលមានតម្រូវការ។

៣.៧. បុគ្គលរាយការណ៍ត្រូវយកចិត្តទុកដាក់ជាពិសេសចំពោះទំនាក់ទំនងធនាគារឆ្លើយឆ្លង និងទំនាក់ទំនងប្រហាក់ប្រហែលថ្មី ឬមានស្រាប់ជាមួយគ្រឹះស្ថានហិរញ្ញវត្ថុមកពីប្រទេស ឬយុត្តាធិការដែលពុំអនុវត្តពេញលេញនូវវិធានការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ដែលទទួលស្គាល់ជាអន្តរជាតិ ឬស្ថិតក្រោមការស៊ើបអង្កេតការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ឬមិនស្ថិតក្រោមវិធានការត្រួតពិនិត្យ ឬបទប្បញ្ញត្តិពាក់ព័ន្ធនឹងការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម។ វិធានការបន្ថែមការយកចិត្តទុកដាក់ស្គាល់អតិថិជនត្រូវអនុវត្តចំពោះរាល់ប្រតិបត្តិការដែលធ្វើឡើងតាមរយៈទំនាក់ទំនងធនាគារឆ្លើយឆ្លង និងទំនាក់ទំនងប្រហាក់ប្រហែល។

៣.៨ បុគ្គលរាយការណ៍ត្រូវពិនិត្យឡើងវិញនូវទំនាក់ទំនងធនាគារឆ្លើយឆ្លង និងទំនាក់ទំនងប្រហាក់ប្រហែលដែលមានស្រាប់ ដើម្បីធានាការអនុវត្តឱ្យស្របតាមការតម្រូវនានារបស់សេចក្តីណែនាំនេះ។

## ៤. **ទណ្ឌកម្ម**

បុគ្គលរាយការណ៍ណាដែលមិនអនុវត្តតាមសេចក្តីណែនាំនេះត្រូវទទួលរងទណ្ឌកម្ម ដូចមានចែងក្នុងមាត្រា៣៦ និងមាត្រា៣៧ នៃច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម។

ទទួលបានសេចក្តីណែនាំនេះគ្រប់បុគ្គលរាយការណ៍ត្រូវអនុវត្តតាមសេចក្តីណែនាំនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃអង្គារ ៩កើត ខែបុស្ស ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី១១ ខែមករា ឆ្នាំ២០២២

**អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា**
**ប្រធាន**

**សាយ សំអាត**

**ចម្លងជូន៖**

- ការិយាល័យទីស្តីការគណៈរដ្ឋមន្ត្រី
- គណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ
- ក្រុមប្រឹក្សាភិបាលអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា
- ឯកសារ-កាលប្បវត្តិ

# សេចក្តីណែនាំ
# ស្តីពី
# ការត្រួតពិនិត្យផ្ទៃក្នុងសម្រាប់បុគ្គលរាយការណ៍

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា**

លេខ ៩១២.០២២.០០៨ ណ.ក.សា-ន

# សេចក្តីណែនាំ
# ស្តីពី
# ការត្រួតពិនិត្យផ្ទៃក្នុងសម្រាប់បុគ្គលរាយការណ៍

អនុលោមតាមច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម បានប្រកាសឱ្យប្រើដោយព្រះរាជក្រម លេខ នស/រកម/០៦២០/០២១ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២០ អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា បានចេញសេចក្តីណែនាំស្តីពីការត្រួតពិនិត្យផ្ទៃក្នុងសម្រាប់បុគ្គលរាយការណ៍។

## ១. វិសាលភាព

សេចក្តីណែនាំនេះត្រូវអនុវត្តចំពោះបុគ្គលរាយការណ៍ ដូចមានចែងក្នុងមាត្រា៤ នៃច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម។ សេចក្តីណែនាំនេះត្រូវអនុវត្តផងដែរចំពោះបុគ្គលរាយការណ៍ដែលស្ថិតនៅក្នុងក្រុមហិរញ្ញវត្ថុ ឬបុគ្គលរាយការណ៍ដែលមានសាខា ឬបុត្តសម្ព័ន្ធនៅបរទេសដែលខ្លួនកាន់កាប់ភាគហ៊ុនភាគច្រើន។

## ២. ហានិភ័យ និងការត្រួតពិនិត្យផ្ទៃក្នុង

២.១. បុគ្គលរាយការណ៍ត្រូវយល់ដឹងអំពីហានិភ័យសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មដែលបានតម្រូវឱ្យវាយតម្លៃស្របតាមមាត្រា៨ នៃច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងបទប្បញ្ញត្តិពាក់ព័ន្ធ។ បុគ្គលរាយការណ៍ត្រូវធានាថា លទ្ធផលនៃការវាយតម្លៃហានិភ័យត្រូវបានផ្សព្វផ្សាយដល់បុគ្គលិកពាក់ព័ន្ធ និងគណៈគ្រប់គ្រងទាំងអស់ ជាព័ត៌មាន និងសម្រាប់ការបណ្តុះបណ្តាល។

២.២. បុគ្គលរាយការណ៍ត្រូវមាននិងអនុវត្តឱ្យមានប្រសិទ្ធភាពនូវគោលនយោបាយ នីតិវិធី និងប្រព័ន្ធនិងការត្រួតពិនិត្យផ្ទៃក្នុងសម្រាប់ការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម។ គោលនយោបាយ នីតិវិធី និងប្រព័ន្ធនិងការត្រួតពិនិត្យផ្ទៃក្នុងត្រូវមានការចែងលម្អិតអំពីការយកចិត្តទុកដាក់ស្គាល់អតិថិជន ការអនុវត្តការគ្រប់គ្រងហានិភ័យ កាតព្វកិច្ចរក្សាទុកឯកសារកត់ត្រា កាតព្វកិច្ចយកចិត្តទុកដាក់ស្គាល់អតិថិជនជាប្រចាំ នីតិវិធីរាយការណ៍ប្រតិបត្តិការ និងកាតព្វកិច្ចពាក់ព័ន្ធផ្សេងទៀតដែលបានកំណត់ដោយច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ស្របតាមការតម្រូវនៃបទប្បញ្ញត្តិច្បាប់ និងស្របគ្នានឹងលក្ខណៈ និងទំហំនៃបុគ្គលរាយការណ៍ ភាពស្មុគស្មាញនៃប្រតិបត្តិការ និងកម្រិតហានិភ័យសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មដែលបានវាយតម្លៃរួច។



ប្រអប់សំបុត្រលេខ ៦៧ ឡូត៍លេខ ២២-២៤ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ www.nbc.org.kh/cafiu cafiu_info@nbc.org.kh

២.៣. បុគ្គលរាយការណ៍ត្រូវត្រួតពិនិត្យ និងពិនិត្យឡើងវិញនូវគោលនយោបាយ នីតិវិធី និងប្រព័ន្ធនិងការត្រួតពិនិត្យផ្ទៃក្នុង។

២.៤. បុគ្គលរាយការណ៍ត្រូវពិនិត្យឡើងវិញ វាយតម្លៃជាទៀងទាត់ និងធ្វើបច្ចុប្បន្នកម្មគោលនយោបាយ នីតិវិធី និងប្រព័ន្ធនិងការត្រួតពិនិត្យផ្ទៃក្នុងឱ្យស្របតាមការប្រែប្រួល និងការអភិវឌ្ឍនៃផលិតផល សេវាកម្ម និងបច្ចេកវិទ្យាព័ត៌មានវិទ្យារបស់ខ្លួន ព្រមទាំងនិន្នាការនៃបច្ចេកទេសសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ទាំងនៅកម្រិតតាមវិស័យ និងថ្នាក់ជាតិ។ បុគ្គលរាយការណ៍ត្រូវកែប្រែជាចាំបាច់នូវគោលនយោបាយ នីតិវិធី និងការត្រួតពិនិត្យផ្ទៃក្នុង ដើម្បីធានាពីភាពគ្រប់គ្រាន់សមស្រប និងស្របគ្នានឹងកម្រិតហានិភ័យដែលបានវាយតម្លៃថ្មីៗ ទាំងនៅកម្រិតស្ថាប័ន វិស័យ និងថ្នាក់ជាតិ។

២.៥. បុគ្គលរាយការណ៍ត្រូវធានាឱ្យមានការធ្វើសវនកម្មឯករាជ្យ (independent internal and external audit) ជាទៀងទាត់ ដោយពិនិត្យឡើងវិញពីភាពគ្រប់គ្រាន់និងប្រសិទ្ធភាពនៃការអនុវត្តគោលនយោបាយ នីតិវិធី និងប្រព័ន្ធនិងការត្រួតពិនិត្យផ្ទៃក្នុង ស្របតាមការតម្រូវនៃច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម។

២.៦. បុគ្គលរាយការណ៍ត្រូវធានាថាតួនាទីនិងភារកិច្ចរបស់សវនករឯករាជ្យផ្ទៃក្នុងត្រូវបានកំណត់ និងចងក្រងជាឯកសារឱ្យបានច្បាស់លាស់ ហើយយ៉ាងហោចណាស់ត្រូវ៖

ក- ធ្វើតេស្តពីប្រសិទ្ធភាពនៃគោលនយោបាយ នីតិវិធី និងប្រព័ន្ធនិងការត្រួតពិនិត្យផ្ទៃក្នុង

ខ- រាយការណ៍ពីភាពគ្រប់គ្រាន់នៃយន្តការត្រួតពិនិត្យការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម រួមមានការតែងតាំងមន្ត្រីប្រតិបត្តិ កម្មវិធីបណ្តុះបណ្តាលនិងលើកកម្ពស់ការយល់ដឹងដល់បុគ្គលិក ភ្នាក់ងារ និងតំណាងចែកចាយ យន្តការតាមដាននិងវាយតម្លៃនិយោជិត និងនីតិវិធីសវនកម្មផ្ទៃក្នុងស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និង

គ- រាយការណ៍ពីវិធានការនានាដែលកំពុងអនុវត្តថាតើមានសង្គតិភាពរវាងគ្នា និងជាមួយការវិវត្តនិងការប្រែប្រួលថ្មីៗនៃកាតព្វកិច្ចប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម។

២.៧. បុគ្គលរាយការណ៍ត្រូវធានាថា សវនករត្រូវរាយការណ៍ពីលទ្ធផលនៃការធ្វើសវនកម្មជាទៀងទាត់។ របាយការណ៍សវនកម្មនេះត្រូវគូសបញ្ជាក់ពីចំណុចខ្វះខាតនៃវិធានការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរបស់បុគ្គលរាយការណ៍។ បុគ្គលរាយការណ៍ត្រូវចាត់វិធានការចាំបាច់នានា ដើម្បីកែតម្រូវចំណុចខ្វះខាតទាំងនេះ។

២.៨. បុគ្គលរាយការណ៍ត្រូវមានប្រព័ន្ធគ្រប់គ្រងព័ត៌មានសមស្រប ដើម្បីកំណត់ ស្វែងរក និងពិនិត្យពិច័យទំនាក់ទំនងអាជីវកម្មនិងប្រតិបត្តិការម្តងម្កាលដែលត្រូវបានសង្ស័យឬមានមូលដ្ឋានសង្ស័យសមស្របថាពាក់ព័ន្ធនឹងផលដែលបានមកពីសកម្មភាពខុសច្បាប់ ឬអតិថិជនជាប់ពាក់ព័ន្ធនឹងការសម្អាតប្រាក់ឬហិរញ្ញប្បទានភេរវកម្ម។ ប្រព័ន្ធគ្រប់គ្រងព័ត៌មានត្រូវផ្តល់ព័ត៌មានទាន់ពេលវេលាជាទៀងទាត់ដល់បុគ្គលរាយការណ៍ ដើម្បីឱ្យបុគ្គលរាយការណ៍អាចស្វែងរកនិងរាយការណ៍សកម្មភាពសង្ស័យ។

២.៩. បុគ្គលរាយការណ៍ត្រូវមានយន្តការរាយការណ៍សម្រាប់ស្វែងរក និងបញ្ជូនរបាយការណ៍ប្រតិបត្តិការសង្ស័យ និង/ឬឯកសារពាក់ព័ន្ធទៅអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា ដោយរក្សាឱ្យបាននូវសុវត្ថិភាព និងការសម្ងាត់។

## ៣. សុចរិតភាពរបស់និយោជិត

បុគ្គលរាយការណ៍ត្រូវបង្កើតប្រព័ន្ធវាយតម្លៃនិយោជិត ដើម្បីតាមដាននិងវាយតម្លៃគ្រប់ជ្រុងជ្រោយពីនិយោជិតទាំងអស់ រួមទាំងនិយោជិតថ្មី និងធានាការពារសមត្ថភាពជំនាញ និងសុចរិតភាពរបស់និយោជិត។ ប្រព័ន្ធវាយតម្លៃនិយោជិតត្រូវពិនិត្យ និងរក្សាទុកនូវព័ត៌មានផ្ទាល់របស់និយោជិត ដែលយ៉ាងហោចណាស់រួមមាន លិខិតថ្កោលទោស ប្រវត្តិការងារ និងហិរញ្ញវត្ថុ ព្រមទាំងព័ត៌មាននៃការរងវិធានការត្រួតពិនិត្យនិងបញ្ញត្តិកម្ម ដែលត្រូវអនុវត្តចំពោះនិយោជិតទាំងអស់ និងជាផ្នែកមួយនៃដំណើរការជ្រើសរើសបុគ្គលិកថ្មី។

## ៤. មន្ត្រីប្រតិបត្តិសម្រាប់ការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម

៤.១. បុគ្គលរាយការណ៍ត្រូវតែងតាំងមន្ត្រីប្រតិបត្តិមួយរូប ស្របតាមមាត្រា១៧ នៃច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ដោយភ្ជាប់មកជាមួយនូវប្រវត្តិរូបរបស់មន្ត្រីនោះ។ ការតែងតាំងមន្ត្រីប្រតិបត្តិត្រូវទទួលបានការសម្រេចពីអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា។

៤.២. បុគ្គលរាយការណ៍ត្រូវជូនដំណឹងមកអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា អំពីការផ្លាស់ប្តូរ ឬការលាឈប់របស់មន្ត្រីប្រតិបត្តិ ដោយមានការចាត់តាំងមន្ត្រីជាន់ខ្ពស់សម្រាប់ទំនាក់ទំនងជាបណ្តោះអាសន្ន ជាមួយអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា ដើម្បីរក្សានិរន្តរភាពនៃកាតព្វកិច្ចប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម។ បុគ្គលរាយការណ៍ត្រូវស្នើសុំការសម្រេចពីអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា លើការតែងតាំងមន្ត្រីប្រតិបត្តិថ្មី យ៉ាងយូរត្រឹមរយៈពេល ១ (មួយ) ខែ បន្ទាប់ពីការផ្លាស់ប្តូរ ឬការលាឈប់របស់មន្ត្រីប្រតិបត្តិ។

៤.៣. បុគ្គលរាយការណ៍ត្រូវកំណត់តួនាទីនិងភារកិច្ចរបស់មន្ត្រីប្រតិបត្តិឱ្យបានច្បាស់លាស់ និងជាលាយលក្ខណ៍អក្សរ។ តួនាទីនិងភារកិច្ចរបស់មន្ត្រីប្រតិបត្តិក្នុងការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម យ៉ាងហោចណាស់ ត្រូវជានាៈ

ក- ការអនុវត្តគោលនយោបាយប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម

ខ- ការបង្កើត ការកែលម្អ និងការអនុវត្តប្រកបដោយប្រសិទ្ធភាពនូវនីតិវិធីប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មសមស្របមួយ រួមមានគោលនយោបាយទទួលស្គាល់អតិថិជន ការយកចិត្តទុកដាក់ស្គាល់អតិថិជន ការអនុវត្តលើការគ្រប់គ្រងហានិភ័យ ការរក្សាទុកឯកសារកត់ត្រា ការតាមដានជាប្រចាំ និងការរាយការណ៍ពីប្រតិបត្តិការ និងកាតព្វកិច្ចពាក់ព័ន្ធផ្សេងៗ ដែលបានកំណត់ដោយច្បាប់និងបទប្បញ្ញត្តិស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម

គ- ការតាមដាន និងការវាយតម្លៃជាទៀងទាត់លើវិធីសាស្ត្រប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ដើម្បីធានាថា គោលនយោបាយ នីតិវិធី និងប្រព័ន្ធនិងការត្រួតពិនិត្យផ្ទៃក្នុង មានលក្ខណៈគ្រប់គ្រាន់ដើម្បីឆ្លើយតបនឹងការប្រែប្រួលនៃវិធីសាស្ត្រនិងនិន្នាការនៃសំអាងនៃបទល្មើស និងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម

ឃ- ការរក្សាសុវត្ថិភាពនៃមធ្យោបាយបញ្ជូនព័ត៌មានរវាងមន្ត្រីប្រតិបត្តិ និងនិយោជិត និង/ឬអ្នកពាក់ព័ន្ធផ្សេងទៀត និងការរក្សាការសម្ងាត់នៃព័ត៌មាន

ង- និយោជិតទាំងអស់បានយល់ដឹងអំពីវិធានការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម រួមមានគោលនយោបាយ នីតិវិធី យន្តការត្រួតពិនិត្យផ្ទៃក្នុង និងបណ្តាញរាយការណ៍ ដើម្បីធានាប្រសិទ្ធភាពនៃវិធានការទាំងនោះ

ច- ការកំណត់ហានិភ័យនៃការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ដែលពាក់ព័ន្ធនឹងផលិតផលឬសេវាថ្មី ប្រព័ន្ធចែកចាយថ្មី ឬដែលកើតឡើងពីការប្រែប្រួលនៃប្រតិបត្តិការរបស់បុគ្គលរាយការណ៍ រួមមានការដាក់ឱ្យប្រើប្រាស់បច្ចេកវិទ្យាថ្មី និងខ្សែសង្វាក់ផលិតកម្មថ្មី ជាដើម

ឆ- ការបញ្ជូនរបាយការណ៍ដូចបានកំណត់នៅក្នុងមាត្រា១២ នៃច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ទៅកាន់អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា

ជ- ការគ្រប់គ្រងលើដំណើរការវាយតម្លៃហានិភ័យសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មជាប្រចាំ និង

ឈ-ការប្រតិបត្តិរបស់និយោជិត ស្របតាមការតម្រូវនៃគោលនយោបាយ នីតិវិធី ច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងអនុសាសន៍របស់អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា។

៤.៤. មន្ត្រីប្រតិបត្តិត្រូវមានចំណេះដឹង ជំនាញ និងបទពិសោធន៍ ដើម្បីអនុវត្តតួនាទីនិងភារកិច្ចរបស់ខ្លួនប្រកបដោយការទទួលខុសត្រូវខ្ពស់ និងមានប្រសិទ្ធភាព ព្រមទាំងពុំមានការជ្រៀតជ្រែកពីភាគីណាមួយ។ មន្ត្រីប្រតិបត្តិអាចចូលយក និងមានសិទ្ធិប្រើប្រាស់គ្រប់ឯកសារ និងព័ត៌មានទាំងអស់ពីផ្នែកផ្សេងៗ បុត្តសម្ព័ន្ធ និងសាខា ទាក់ទងនឹងគណនី និងប្រតិបត្តិការរបស់អតិថិជន។

៤.៥. គោលនយោបាយនិងនីតិវិធីស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មរបស់បុគ្គលរាយការណ៍ ត្រូវអនុញ្ញាតឱ្យមន្ត្រីប្រតិបត្តិទទួលរបាយការណ៍អំពីប្រតិបត្តិការខុសប្រក្រតីដោយផ្ទាល់ពីនិយោជិតពាក់ព័ន្ធ ទោះបីពុំបានដឹងច្បាស់ថាប្រតិបត្តិការនោះជាសកម្មភាពខុសច្បាប់ ឬពិតជាកើតឡើងក៏ដោយ។ មន្ត្រីប្រតិបត្តិត្រូវវាយតម្លៃភ្លាមៗនូវរបាយការណ៍ប្រតិបត្តិការខុសប្រក្រតីនៅពេលទទួលបានពីនិយោជិត។ ប្រសិនបើរបាយការណ៍នោះបានបំពេញតាមលក្ខខណ្ឌដូចមានចែងក្នុងមាត្រា១២ និងមាត្រា១៣ នៃច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម មន្ត្រីប្រតិបត្តិត្រូវបញ្ជូនរបាយការណ៍ប្រតិបត្តិការសង្ស័យនោះទៅអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា។

## ៥. កម្មវិធីបង្កើនការយល់ដឹង និងបណ្តុះបណ្តាលបុគ្គលិក

៥.១. បុគ្គលរាយការណ៍ត្រូវធានាឱ្យមានកម្មវិធីបង្កើនការយល់ដឹងនិងបណ្តុះបណ្តាលស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មជាប្រចាំឱ្យបានគ្រប់គ្រាន់ដល់និយោជិត ភ្នាក់ងារ និងតំណាងចែកចាយ ដោយស្របតាមទំហំអាជីវកម្ម និងកម្រិតហានិភ័យសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មរបស់បុគ្គលរាយការណ៍។ កម្មវិធីបង្កើនការយល់ដឹងនិងការបណ្តុះបណ្តាលនេះត្រូវផ្តល់ជូនគ្រប់និយោជិតទាំងអស់។

៥.២. កម្មវិធីបណ្តុះបណ្តាលនេះគឺដើម្បីធានាការអនុវត្តគោលនយោបាយ និងនីតិវិធីប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ឱ្យមានប្រសិទ្ធភាព និងការយល់ដឹងអំពីហានិភ័យសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មដែលពាក់ព័ន្ធនឹងបុគ្គលរាយការណ៍។

៥.៣. បុគ្គលរាយការណ៍ត្រូវមានមធ្យោបាយសមស្រប ដើម្បីផ្តល់ព័ត៌មានស្តីពីគោលនយោបាយ និងនីតិវិធីប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ដល់និយោជិតគ្រប់លំដាប់ថ្នាក់ ភ្នាក់ងារ និងតំណាងចែកចាយ។

៥.៤. បុគ្គលរាយការណ៍ត្រូវធានាថានិយោជិតយល់ដឹងពីគោលនយោបាយ ការត្រួតពិនិត្យផ្ទៃក្នុង និងសៀវភៅណែនាំអំពីការប្រតិបត្តិនៃការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងការតម្រូវនៃច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម។

៥.៥. បុគ្គលរាយការណ៍ត្រូវរៀបចំ និងកែលម្អសៀវភៅណែនាំអំពីការប្រតិបត្តិនេះ ដែលយ៉ាងហោចណាស់ រួមមាន៖

ក- ច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម

ខ- ស្តង់ដារ និងសេចក្តីណែនាំរបស់ក្រុមការងារហិរញ្ញវត្ថុ និង

គ- គោលការណ៍ណែនាំ ឬនីតិវិធីផ្សេងទៀត ដាក់ចេញដោយអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា។

៥.៦. បុគ្គលរាយការណ៍ត្រូវអនុវត្តកម្មវិធីបណ្តុះបណ្តាលដល់និយោជិត តាមផ្នែកផ្សេងៗ យ៉ាងហោចណាស់ រួមមាន៖

**ក- និយោជិតថ្មី**

ចំណេះដឹងមូលដ្ឋានពាក់ព័ន្ធនឹងច្បាប់និងបទប្បញ្ញត្តិស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងទ្រឹស្តីពាក់ព័ន្ធនឹងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម។

**ខ- និយោជិតជួរមុខ**

និយោជិតដែលទាក់ទងផ្ទាល់ជាមួយអតិថិជន ត្រូវទទួលបានការបណ្តុះបណ្តាលយ៉ាងហោចណាស់ អំពីការកំណត់សញ្ញាណប្រតិបត្តិការ វិធានការចាំបាច់ត្រូវអនុវត្តនៅពេលដែលប្រតិបត្តិការមួយមានលក្ខណៈគួរឱ្យសង្ស័យ កត្តាដែលអាចនាំដល់ការសង្ស័យ ការរាយការណ៍ប្រតិបត្តិការដែលមានទំហំធំ និងវិធានការបន្លឹងការយកចិត្តទុកដាក់ស្គាល់អតិថិជន។

**គ- និយោជិត - ការបើកគណនី/អតិថិជនថ្មី**

និយោជិតដែលទទួលខុសត្រូវបើកគណនី ឬទទួលអតិថិជនថ្មី ត្រូវទទួលបានការបណ្តុះបណ្តាល ដូចគ្នានឹងនិយោជិតជួរមុខ និងយ៉ាងហោចណាស់ ត្រូវទទួលបានការបណ្តុះបណ្តាលពីការកំណត់និងការផ្ទៀងផ្ទាត់អត្តសញ្ញាណអតិថិជន ការបើកគណនី និងការបង្កើតទំនាក់ទំនងអាជីវកម្មជាមួយអតិថិជន។

**ឃ- មន្ត្រីត្រួតពិនិត្យ និងមន្ត្រីគ្រប់គ្រង**

មន្ត្រីត្រួតពិនិត្យ និងមន្ត្រីគ្រប់គ្រងត្រូវទទួលបានការណែនាំកម្រិតខ្ពស់ ដែលគ្របដណ្តប់គ្រប់ទិដ្ឋភាពនៃការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ជាអាទិ៍ ច្បាប់ បទប្បញ្ញត្តិ គោលនយោបាយ និងនីតិវិធី ដែលក្នុងនោះមានការដាក់ទណ្ឌកម្មចំពោះការមិនគោរពតាមកាតព្វកិច្ចនៃការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម។

៥.៧. កម្មវិធីបង្កើនការយល់ដឹង និងបណ្តុះបណ្តាលទាំងនេះ ត្រូវរៀបចំ និងធ្វើបច្ចុប្បន្នកម្មជាទៀងទាត់ រួមទាំងវគ្គសិក្សារំលឹកឡើងវិញជូនដល់និយោជិត។ និយោជិតថ្មីត្រូវទទួលការបណ្តុះបណ្តាលក្នុងរយៈពេល ៣ (បី) ខែ ក្នុងអំឡុងពេលចាប់ផ្តើមបំពេញការងារ ហើយចំពោះនិយោជិតជួរមុខ មន្ត្រីត្រួតពិនិត្យ និងមន្ត្រីគ្រប់គ្រងត្រូវចូលរួមវគ្គសិក្សារំលឹកឡើងវិញយ៉ាងហោចណាស់ មួយដងក្នុងមួយឆ្នាំ។

## ៦. ទណ្ឌកម្មហិរញ្ញវត្ថុតាមគោលដៅប្រឆាំងហិរញ្ញប្បទានភេរវកម្ម

៦.១. បុគ្គលរាយការណ៍ត្រូវចាត់វិធានការចាំបាច់ ដើម្បីធានាការអនុលោមតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ ច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងទណ្ឌកម្មហិរញ្ញវត្ថុតាមគោលដៅប្រឆាំងហិរញ្ញប្បទានភេរវកម្ម។

៦.២. បុគ្គលរាយការណ៍ត្រូវពង្រីកវិសាលភាពនៃយន្តការរាយការណ៍ប្រតិបត្តិការសង្ស័យ ដើម្បីគ្របដណ្តប់លើការផ្តល់ហិរញ្ញប្បទានភេរវកម្ម ឬទ្រព្យសម្បត្តិ ឬមូលនិធិ ឬសេវាផ្សេងៗ ដែលត្រូវបានសង្ស័យថាអាចជាកម្មវត្ថុនៃការដាក់ទណ្ឌកម្មហិរញ្ញវត្ថុតាមគោលដៅ។

៦.៣. បុគ្គលរាយការណ៍ត្រូវរក្សាទុកឯកសារកត់ត្រា ឈ្មោះ និងសញ្ញាសម្គាល់ផ្សេងៗនៃភេរវករដែលស្ថិតក្នុងបញ្ជីរបស់អង្គការសហប្រជាជាតិ និងភេរវករដែលបានកំណត់ដោយអាជ្ញាធរនៃប្រទេសកម្ពុជា ហើយត្រូវផ្គូបផ្គួលកំណត់ត្រាទាំងនេះជាមួយនឹងបញ្ជីឈ្មោះផ្សេងទៀតរបស់បុគ្គលជាប់ឈ្មោះក្នុងបញ្ជី។ ព័ត៌មាននៅក្នុងឯកសារកត់ត្រាត្រូវធ្វើបច្ចុប្បន្នកម្ម និងមានភាពត្រឹមត្រូវ និងមានភាពងាយស្រួលដល់និយោជិតក្នុងការទាញយកមកប្រើប្រាស់ដើម្បីកំណត់ប្រតិបត្តិការសង្ស័យ និងបង្កកគណនី ឬមូលនិធិ ឬសេវាផ្សេងៗ។

៦.៤. បុគ្គលរាយការណ៍ត្រូវផ្ទៀងផ្ទាត់ឈ្មោះអតិថិជនទាំងថ្មី និងមានស្រាប់ ជាមួយនឹងបញ្ជីឈ្មោះភេរវកររបស់អង្គការសហប្រជាជាតិ និងបញ្ជីឈ្មោះភេរវករក្នុងស្រុក។ ប្រសិនបើមានឈ្មោះដូចនៅក្នុងបញ្ជី បុគ្គលរាយការណ៍ត្រូវផ្ទៀងផ្ទាត់ និងបញ្ជាក់ពីអត្តសញ្ញាណអតិថិជនរបស់ខ្លួន។ ប្រសិនបើអតិថិជន និងបុគ្គលជាប់ឈ្មោះក្នុងបញ្ជីជាមនុស្សតែមួយ បុគ្គលរាយការណ៍ត្រូវបង្កកដោយគ្មានបង្អង់និងដោយគ្មានជូនដំណឹងជាមុននូវទ្រព្យសម្បត្តិ ឬមូលនិធិ ឬសេវាផ្សេងៗរបស់អតិថិជនស្របតាមច្បាប់ បទប្បញ្ញត្តិ និងសេចក្តីសម្រេចរបស់តុលាការដែលពាក់ព័ន្ធ ហើយជូនព័ត៌មានភ្លាមទៅអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា។ បុគ្គលរាយការណ៍ត្រូវបញ្ជូនរបាយការណ៍ប្រតិបត្តិការសង្ស័យទៅអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា នៅពេលដែលសង្ស័យថាប្រតិបត្តិការនោះជាប់ទាក់ទងនឹងភេរវកម្ម ឬហិរញ្ញប្បទានភេរវកម្ម។

## ៧. សាខា និងបុត្តសម្ព័ន្ធនៅបរទេស

៧.១. បុគ្គលរាយការណ៍ដែលជាក្រុមហិរញ្ញវត្ថុ ឬស្ថិតនៅក្នុងក្រុមហិរញ្ញវត្ថុ ឬបុគ្គលរាយការណ៍ដែលមានសាខា ឬបុត្តសម្ព័ន្ធនៅបរទេសដែលខ្លួនកាន់កាប់ភាគហ៊ុនភាគច្រើន ត្រូវអនុវត្តកម្មវិធីរួមរបស់ក្រុមហិរញ្ញវត្ថុ។

៧.២. កម្មវិធីរួមរបស់ក្រុមហិរញ្ញវត្ថុ ត្រូវរួមបញ្ចូល៖

ក- ការតម្រូវទាំងអស់ ដែលបានកំណត់ក្នុងចំណុច ២ ដល់ ៦ នៃសេចក្តីណែនាំនេះ

ខ- គោលនយោបាយ និងនីតិវិធី នៃការចែករំលែកព័ត៌មានរវាងសមាជិកក្នុងក្រុមហិរញ្ញវត្ថុ ក្នុងគោលបំណងអនុវត្ត ការយកចិត្តទុកដាក់ស្គាល់អតិថិជន និងគ្រប់គ្រងហានិភ័យសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម

គ- ការចែករំលែកព័ត៌មាននានារបស់អតិថិជន ក្នុងកម្រិតជាក្រុមលើការធ្វើសវនកម្ម ការប្រតិបត្តិតាម និងការគ្រប់គ្រងនិងកាត់បន្ថយហានិភ័យសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម។ ការចែករំលែកនេះ សម្រាប់គោលបំណង ប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និង

ឃ- គោលនយោបាយ និងនីតិវិធីដើម្បីរក្សាការសម្ងាត់ ប្រើប្រាស់ព័ត៌មានដែលបានចែករំលែកឱ្យបានសមស្រប រវាងសមាជិកក្នុងក្រុមហិរញ្ញវត្ថុ និងការពារការបែកធ្លាយព័ត៌មាន។

៧.៣. បុគ្គលរាយការណ៍ដែលមានសាខា និងបុត្តសម្ព័ន្ធនៅបរទេសដែលខ្លួនកាន់កាប់ភាគហ៊ុនភាគច្រើនត្រូវតម្រូវឱ្យ សាខា និងបុត្តសម្ព័ន្ធទាំងនោះអនុវត្តវិធានការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ដែលស្របនឹងការតម្រូវ នៅក្នុងច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងសេចក្តីណែនាំនេះ៖

ក- នៅពេលដែលច្បាប់របស់ប្រទេសដែលសាខា ឬបុត្តសម្ព័ន្ធរបស់បុគ្គលរាយការណ៍បោះទីតាំងនៅបរទេស មានភាពតឹងរ៉ឹងជាងច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងសេចក្តីណែនាំនេះ បុគ្គលរាយការណ៍ អាចអនុវត្តតាមការតម្រូវនៃការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មនៅប្រទេសនោះ ក្នុងករណីដែលអង្គភាព ស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា អនុញ្ញាត។

ខ- នៅពេលដែលការតម្រូវនៃការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មរបស់ប្រទេសដែលសាខា ឬបុត្តសម្ព័ន្ធរបស់បុគ្គលរាយការណ៍បោះទីតាំងនៅបរទេសមានភាពធូរស្រាលជាងនៅប្រទេសកម្ពុជា បុគ្គលរាយការណ៍ ត្រូវធានាឱ្យសាខា ឬបុត្តសម្ព័ន្ធនេះ អនុវត្តតាមការតម្រូវនៃការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មនៅ ប្រទេសកម្ពុជា លើកលែងតែច្បាប់នៃប្រទេសដែលសាខា ឬបុត្តសម្ព័ន្ធនៅបរទេសធ្វើប្រតិបត្តិការ មិនអនុញ្ញាត។

គ- ក្នុងករណីដែលច្បាប់នៃប្រទេសដែលសាខា ឬបុត្តសម្ព័ន្ធរបស់បុគ្គលរាយការណ៍បោះទីតាំងនៅបរទេស មិន អនុញ្ញាតឱ្យសាខា ឬក្រុមហ៊ុនបុត្តសម្ព័ន្ធនេះអនុវត្តតាមការតម្រូវនៃការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម នៅប្រទេសកម្ពុជា ក្រុមហិរញ្ញវត្ថុត្រូវ៖

១/. បង្កើតវិធានការបន្ថែមសមស្រប ដើម្បីគ្រប់គ្រង និងកាត់បន្ថយហានិភ័យសម្អាតប្រាក់និងហិរញ្ញប្បទាន ភេរវកម្ម និង

២/. ជូនដំណឹងមកអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា។

៧.៤. កាតព្វកិច្ចនៃមាត្រា១៥ នៃច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម មិនរារាំងចំពោះការធ្វើ ទំនាក់ទំនងសម្ងាត់រវាងបុគ្គលរាយការណ៍ដែលស្ថិតនៅក្នុងក្រុមហិរញ្ញវត្ថុតែមួយ ដែលតម្រូវឱ្យអនុវត្តតាមចំណុច ៧.២ (ខ) និង(គ) នៃសេចក្តីណែនាំនេះ។ បុគ្គលរាយការណ៍ត្រូវបង្កើតឱ្យមានយន្តការនៃការចែករំលែក និងការប្រើប្រាស់ ព័ត៌មាននៅក្នុងក្រុមហិរញ្ញវត្ថុតែមួយ ដើម្បីធានាឱ្យមានសុវត្ថិភាព និងការរក្សាការសម្ងាត់ព័ត៌មាន។

## ៨. សិទ្ធិអំណាចត្រួតពិនិត្យ

ដើម្បីធានាឱ្យអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជាអនុវត្តតួនាទីនិងភារកិច្ចរបស់ខ្លួនស្របតាមកថាខណ្ឌទី២ នៃមាត្រា២៣ នៃច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម បុគ្គលរាយការណ៍ត្រូវគោរពសិទ្ធិអំណាចរបស់អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា ដូចខាងក្រោម៖

ក- ចូលទីតាំងរបស់បុគ្គលរាយការណ៍ ក្នុងគោលបំណងនៃការត្រួតពិនិត្យ ការថតចម្លង ឬការប្រមូលឯកសារ ឬព័ត៌មានផ្សេងៗ

ខ- កំណត់ឱ្យបុគ្គលរាយការណ៍ផ្តល់ឯកសារ របាយការណ៍ ឬព័ត៌មានផ្សេងៗ ដែលចាំបាច់ និង

គ- តម្រូវឱ្យគណៈគ្រប់គ្រង មន្ត្រី និងនិយោជិត របស់បុគ្គលរាយការណ៍ផ្តល់ព័ត៌មាន ឬជំនួយនានា ដែលចាំបាច់។

## ៩. ទណ្ឌកម្ម

បុគ្គលរាយការណ៍ណាដែលមិនគោរពតាមសេចក្តីណែនាំនេះត្រូវទទួលរងទណ្ឌកម្ម ដូចមានចែងក្នុងមាត្រា៣៦ និងមាត្រា៣៧ នៃច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម។

ទទួលបានសេចក្តីណែនាំនេះគ្រប់បុគ្គលរាយការណ៍ត្រូវអនុវត្តតាមសេចក្តីណែនាំនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃអង្គារ ៩កើត ខែបុស្ស ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី១១ ខែមករា ឆ្នាំ២០២២

**អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា**

**ប្រធាន**

**សាយ សំអាត**

**ចម្លងជូន៖**

- ការិយាល័យទីស្តីការគណៈរដ្ឋមន្ត្រី
- គណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ
- ក្រុមប្រឹក្សាភិបាលអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា
- ឯកសារ-កាលប្បវត្តិ

# សេចក្តីណែនាំ
# ស្តីពី
# វិធានការយកចិត្តទុកដាក់ស្គាល់អតិថិជន

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ៩១២.០២១.០៩៤០.ស.ក.ណ.ន

# សេចក្តីណែនាំ
# ស្តីពី
# វិធានការយកចិត្តទុកដាក់ស្គាល់អតិថិជន

អនុលោមតាមច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម បានប្រកាសឱ្យប្រើដោយព្រះរាជក្រម លេខ នស/រកម/០៦២០/០២១ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២០ អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា បានចេញសេចក្តីណែនាំស្តីពីវិធានការយកចិត្តទុកដាក់ស្គាល់អតិថិជន។

## ១. វិសាលភាព

សេចក្តីណែនាំនេះត្រូវអនុវត្តចំពោះបុគ្គលរាយការណ៍ទាំងអស់ ដូចមានចែងក្នុងមាត្រា៤ នៃច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម រួមទាំង បុគ្គលឬវិជ្ជាជីវៈ ដែលត្រូវបានកំណត់ជាបុគ្គលរាយការណ៍ ស្របតាមកថាខណ្ឌទី១៥ នៃមាត្រា៤ នៃច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម។

## ២. និយមន័យនៃពាក្យបច្ចេកទេស

វាក្យសព្ទបច្ចេកទេសសំខាន់ៗ ដែលប្រើនៅក្នុងសេចក្តីណែនាំនេះត្រូវបានកំណត់និយមន័យ ដូចខាងក្រោម៖

ក- "សិទ្ធិជាម្ចាស់កម្មសិទ្ធិ" លើនីតិបុគ្គល សម្រាប់គោលបំណងនៃកថាខណ្ឌទី១០(ក) នៃមាត្រា៣ នៃច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងសេចក្តីណែនាំនេះ មានន័យថា ការកាន់កាប់ភាគហ៊ុន ឬសិទ្ធិបោះឆ្នោតដោយផ្ទាល់ឬដោយប្រយោល ស្មើ ឬលើស ២០ភាគរយ។

ខ- "សមាជិកគ្រួសារ" មានន័យថា បុគ្គលដែលមានទំនាក់ទំនងជាមួយបុគ្គលពាក់ព័ន្ធនយោបាយ មានដូចជា៖

i. ឳពុកម្តាយ
ii. បងប្អូនបង្កើត
iii. ប្តី ប្រពន្ធ
iv. កូន ឬ
v. ឳពុកម្តាយក្មេក។

គ- "សមាគតជិតស្និទ្ធ" មានន័យថា បុគ្គលដែលប្រគល់តួនាទីឱ្យធ្វើប្រតិបត្តិការហិរញ្ញវត្ថុ ទាំងក្នុងស្រុកនិងអន្តរជាតិជំនួសឱ្យបុគ្គលពាក់ព័ន្ធនយោបាយ។ បុគ្គលដែលត្រូវបានគេស្គាល់ជាសាធារណៈថាមានទំនាក់ទំនងផ្ទាល់ខ្លួន អាជីវកម្ម ឬវិជ្ជាជីវៈ ជិតស្និទ្ធជាមួយបុគ្គលពាក់ព័ន្ធនយោបាយ រួមមាន៖



ប្រអប់សំបុត្រលេខ ២៥, ឡូត៍លេខ ៤៨ ផ្លូវលេខ ១០២ កែងនឹងផ្លូវលេខ ១៩ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ , ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ / ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

i. បុគ្គលដែលពឹងផ្អែកផ្នែកហិរញ្ញវត្ថុលើបុគ្គលពាក់ព័ន្ធនយោបាយ ដូចជា បុគ្គលដែលទទួលប្រាក់បៀវត្សរ៍ពីបុគ្គលពាក់ព័ន្ធនយោបាយ ដូចជា អ្នកបើកបរ អង្គរក្ស លេខាធិការ ជាដើម
ii. ដៃគូអាជីវកម្ម ឬសមាគតជាមួយបុគ្គលពាក់ព័ន្ធនយោបាយ
iii. សមាជិកសំខាន់ៗដែលនៅក្នុងអង្គភាពជាមួយបុគ្គលពាក់ព័ន្ធនយោបាយ
iv. បុគ្គលដែលធ្វើការយ៉ាងជិតស្និទ្ធជាមួយបុគ្គលពាក់ព័ន្ធនយោបាយ ដូចជា អ្នករួមការងារ ជាដើម ឬ
v. មិត្តភ័ក្តិជិតស្និទ្ធ។

ឃ- "ប្រតិបត្តិការម្តង ឬម្តងម្កាល" មានន័យថា ប្រតិបត្តិការដែលធ្វើឡើងខុសពីធម្មតា និង/ឬ ខុសពីទម្លាប់ ដែលមិនស្របតាមសាវតាររបស់អតិថិជន។

ង- "គណៈគ្រប់គ្រងជាន់ខ្ពស់" មានន័យថា បុគ្គលដែលមានសិទ្ធិ ឬការទទួលខុសត្រូវលើការគ្រប់គ្រងសកម្មភាពប្រចាំថ្ងៃរបស់បុគ្គលរាយការណ៍ ឬនីតិបុគ្គល និងលើការរៀបចំផែនការ ការដឹកនាំ និងការត្រួតពិនិត្យ លើបុគ្គលរាយការណ៍ ឬនីតិបុគ្គល។

## ៣. ការវាយតម្លៃហានិភ័យ

### ៣.១ វិធីសាស្ត្រផ្អែកលើហានិភ័យ

បុគ្គលរាយការណ៍ ត្រូវអនុវត្តវិធីសាស្ត្រផ្អែកលើហានិភ័យ ដើម្បីកំណត់អត្តសញ្ញាណ វាយតម្លៃ គ្រប់គ្រង និងកាត់បន្ថយហានិភ័យសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ស្របតាមកថាខណ្ឌទី១ និងកថាខណ្ឌទី៣ នៃមាត្រា៨ នៃច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម។ ដំណើរការនៃការវាយតម្លៃហានិភ័យ ត្រូវបញ្ចូលការវាយតម្លៃប្រភេទហានិភ័យ ដូចខាងក្រោម៖

ក- ហានិភ័យអតិថិជន

ខ- ហានិភ័យភូមិសាស្ត្រពាក់ព័ន្ធនឹងប្រតិបត្តិការ អតិថិជន ផលិតផលនិងសេវាកម្ម និងប្រភេទផ្សេងៗទៀត

គ- ហានិភ័យពាក់ព័ន្ធនឹងផលិតផល សេវាកម្ម ប្រព័ន្ធចែកចាយ និង/ឬបច្ចេកវិទ្យា និង

ឃ- កត្តាផ្សេងៗដែលបង្កឱ្យមានហានិភ័យសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម នៅក្នុងឬពាក់ព័ន្ធបុគ្គលរាយការណ៍។

### ៣.២ ការរក្សាទុកកំណត់ត្រា និងការតាមដានជាប្រចាំ

ការវាយតម្លៃដែលត្រូវបានធ្វើឡើងស្របតាមចំណុចទី៣ នៃសេចក្តីណែនាំនេះ ត្រូវមានកំណត់ត្រាជាលាយលក្ខណ៍អក្សរ និងត្រួតពិនិត្យឡើងវិញប្រចាំគ្រា រក្សាឱ្យមានបច្ចុប្បន្នភាព និងចងក្រងជាឯកសារ។ នៅពេលមានការដាក់ឱ្យប្រើប្រាស់ផលិតផល សេវាកម្ម ប្រព័ន្ធចែកចាយ និង/ឬបច្ចេកវិទ្យាថ្មី បុគ្គលរាយការណ៍ត្រូវវាយតម្លៃហានិភ័យសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ជាមុនសិនមុននឹងដាក់ឱ្យប្រើប្រាស់។

### ៣.៣ មូលដ្ឋាននៃការវាយតម្លៃហានិភ័យ

លក្ខណៈ វិសាលភាព និងភាពស្មុគស្មាញនៃការវាយតម្លៃហានិភ័យស្របតាមកថាខណ្ឌទី៣ នៃមាត្រា៨ នៃច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងចំណុចទី៣ នៃសេចក្តីណែនាំនេះ ត្រូវធ្វើឡើងឱ្យស្របតាមទំហំ និងភាពស្មុគស្មាញនៃអាជីវកម្មរបស់បុគ្គលរាយការណ៍ និងស្ថានភាពហានិភ័យសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ដែលបុគ្គលរាយការណ៍កំពុងធ្វើប្រតិបត្តិការអាជីវកម្ម។

## ៤. ភាតព្វកិច្ចរបស់បុគ្គលរាយការណ៍

### ៤.១ កម្រិតកំណត់នៃការយកចិត្តទុកដាក់ស្គាល់អតិថិជន

៤.១.១ ចំនួនកំណត់នៃការអនុវត្តវិធានការយកចិត្តទុកដាក់ស្គាល់អតិថិជន ដូចមានចែងនៅក្នុងជំពូកទី៣ នៃច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ពាក់ព័ន្ធនឹងប្រតិបត្តិការម្តង ឬម្តងម្កាល មានចំនួនទឹកប្រាក់ ៤០.០០០.០០០ (សែសិបលាន) រៀល ឬរូបិយប័ណ្ណមានតម្លៃស្មើ លើកលែងការផ្ទេរតាមអេឡិចត្រូនិក ឬប្រតិបត្តិការពាក់ព័ន្ធនឹងបុគ្គលរាយការណ៍ ដូចមានចែងក្នុងកថាខណ្ឌទី១០ និងកថាខណ្ឌទី១៣ នៃមាត្រា៤ នៃច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម។

៤.១.២ ចំនួនកំណត់នៃការអនុវត្តវិធានការយកចិត្តទុកដាក់ស្គាល់អតិថិជន ដូចមានចែងក្នុងជំពូកទី៣ នៃច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ពាក់ព័ន្ធនឹងការផ្ទេរមូលនិធិ និងការផ្ទេរប្រាក់តាមអេឡិចត្រូនិក មានចំនួនទឹកប្រាក់ ៤.០០០.០០០ (បួនលាន) រៀល ឬរូបិយប័ណ្ណមានតម្លៃស្មើ។

៤.១.៣ ចំនួនកំណត់នៃការអនុវត្តវិធានការយកចិត្តទុកដាក់ស្គាល់អតិថិជន ដូចមានចែងក្នុងជំពូកទី៣ នៃច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ពាក់ព័ន្ធនឹងបុគ្គលរាយការណ៍ ដែលកំណត់ក្នុងកថាខណ្ឌទី១០ នៃមាត្រា៤ នៃច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម មានចំនួនទឹកប្រាក់ ៦០.០០០.០០០ (ហុកសិបលាន) រៀល ឬរូបិយប័ណ្ណមានតម្លៃស្មើ។

៤.១.៤ កម្រិតកំណត់នៃការអនុវត្តវិធានការយកចិត្តទុកដាក់ស្គាល់អតិថិជន ដូចមានចែងក្នុងជំពូកទី៣ នៃច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មពាក់ព័ន្ធបុគ្គលរាយការណ៍ ដែលកំណត់ក្នុងកថាខណ្ឌទី១៣ នៃមាត្រា៤ នៃច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម មានចំនួនទឹកប្រាក់ ១២.០០០.០០០ (ដប់ពីរលាន) រៀល ឬរូបិយប័ណ្ណមានតម្លៃស្មើ។

### ៤.២ វិធានការប្រកាន់យកដោយបុគ្គលរាយការណ៍ដើម្បីកំណត់អត្តសញ្ញាណ និងផ្ទៀងផ្ទាត់អត្តសញ្ញាណអតិថិជន

៤.២.១ នៅពេលប្រាកដថាមានលក្ខខណ្ឌមួយឬច្រើនសម្រាប់ការអនុវត្តការយកចិត្តទុកដាក់ស្គាល់អតិថិជន ដូចមានចែងក្នុងកថាខណ្ឌទី៤ នៃមាត្រា៨ នៃច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងស្របតាមចំនួនកំណត់និងលក្ខខណ្ឌលើកលែង ដូចមានចែងក្នុងចំណុច ៤.១ នៃសេចក្តីណែនាំនេះ បុគ្គលរាយការណ៍ត្រូវកំណត់អត្តសញ្ញាណនិងផ្ទៀងផ្ទាត់អតិថិជន ដូចមានចែងក្នុងមាត្រា៨ នៃច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងសេចក្តីណែនាំនេះ។

៤.២.២ អតិថិជនដែលជារូបវន្តបុគ្គល

ក- នៅពេលអនុវត្តវិធានការយកចិត្តទុកដាក់ស្គាល់អតិថិជនជារូបវន្តបុគ្គល បុគ្គលរាយការណ៍ត្រូវប្រមូលព័ត៌មានពីអតិថិជនយ៉ាងតិច ដូចខាងក្រោម៖

i. នាមត្រកូល
ii. ថ្ងៃ ខែ ឆ្នាំកំណើត

iii. អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន
iv. មុខរបរ ឬអាជីវកម្ម
v. សញ្ជាតិ
vi. អាសយដ្ឋាន និង
vii. ថាតើរូបវន្តបុគ្គលនោះកំពុងធ្វើប្រតិបត្តិការជំនួសឱ្យបុគ្គលដទៃ។

ខ- ព័ត៌មានដូចមានចែងក្នុងចំណុច ៤.២.២ (ក) នៃសេចក្តីណែនាំនេះ ត្រូវផ្ទៀងផ្ទាត់ជាមួយឯកសារដើម ដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ច ដែលឯកសារទាំងនេះត្រូវមានភ្ជាប់រូបថត និងព័ត៌មាន ដូចមានចែងក្នុង ចំណុច ៤.២.២ (ក) នៃសេចក្តីណែនាំនេះ។

គ- នៅពេលអតិថិជនដែលត្រូវធ្វើការយកចិត្តទុកដាក់ស្គាល់អតិថិជន កំពុងធ្វើប្រតិបត្តិការជំនួសបុគ្គលផ្សេងទៀត បុគ្គលរាយការណ៍ត្រូវកំណត់អត្តសញ្ញាណ និងផ្ទៀងផ្ទាត់អត្តសញ្ញាណបុគ្គលនោះឱ្យបានពេញលេញ ដូចបានកំណត់ នៅក្នុងចំណុច ៤.២.២ (ក) និង ៤.២.២ (ខ) នៃសេចក្តីណែនាំនេះ។

៤.២.៣ អតិថិជនដែលជានីតិបុគ្គល

ក- នៅពេលអនុវត្តវិធានការយកចិត្តទុកដាក់ស្គាល់អតិថិជនជានីតិបុគ្គល បុគ្គលរាយការណ៍ត្រូវប្រមូលព័ត៌មាន ពីអតិថិជនយ៉ាងតិច ដូចខាងក្រោម៖

i. ឈ្មោះដែលបានចុះបញ្ជីរបស់នីតិបុគ្គល
ii. កាលបរិច្ឆេទបង្កើត
iii. លេខចុះបញ្ជីដែលចេញដោយអាជ្ញាធរពាក់ព័ន្ធ
iv. ការិយាល័យចុះបញ្ជី
v. អាសយដ្ឋានទីតាំងអាជីវកម្មមួយ ឬច្រើន
vi. ប្រភេទអាជីវកម្ម
vii. ឈ្មោះ និងអាសយដ្ឋានរបស់នាយក ឬដៃគូរអាជីវកម្ម
viii. ឈ្មោះ និងអាសយដ្ឋានរបស់ភាគទុនិក និង
ix. ឈ្មោះ និងអាសយដ្ឋានរបស់បុគ្គលដែលទទួលសិទ្ធិជាអ្នកតំណាងរបស់នីតិបុគ្គល ឬអត្ថគាហក ចុងក្រោយរបស់នីតិបុគ្គល។

ខ- បុគ្គលរាយការណ៍ផ្ទៀងផ្ទាត់ព័ត៌មានដូចមានចែងក្នុងចំណុច ៤.២.៣ (ក) ក្នុងសេចក្តីណែនាំនេះ ជាមួយ ឯកសារដើម ដូចខាងក្រោម៖

i. អនុស្សរណៈ លក្ខន្តិកៈ ឬវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម ឬភាពជាដៃគូ
ii. ឯកសារចុះបញ្ជីក្រុមហ៊ុនដែលបង្ហាញពីការិយាល័យចុះបញ្ជី និងឈ្មោះនាយក ឬដៃគូរអាជីវកម្ម
iii. ឯកសារចុះបញ្ជីក្រុមហ៊ុនដែលបង្ហាញពីឈ្មោះម្ចាស់ភាគហ៊ុន
iv. សេចក្តីសម្រេចរបស់ក្រុមហ៊ុនដែលប្រគល់សិទ្ធិឱ្យបុគ្គលធ្វើជាតំណាងឱ្យអតិថិជន

v. ការប្រគល់សិទ្ធិ ឬការអនុញ្ញាតដែលចេញឱ្យអតិថិជន ឬបុគ្គលណាមួយ ធ្វើប្រតិបត្តិការជំនួសឱ្យអត្ថគាហកចុងក្រោយរបស់អតិថិជន ដើម្បីធ្វើអាជីវកម្មរបស់ខ្លួន។

គ- បុគ្គលដែលត្រូវកំណត់អត្តសញ្ញាណជា៖

i. នាយក

ii. ដៃគូអាជីវកម្ម ឬ

iii. ភាគទុនិករបស់អតិថិជន ត្រូវតែកំណត់អត្តសញ្ញាណ និងផ្ទៀងផ្ទាត់ ស្របតាមតម្រូវការនៅក្នុងចំណុច ៤.២.២ នៃសេចក្ដីណែនាំនេះ។

ឃ- តម្រូវការ ដូចមានចែងក្នុងចំណុច ៤.២.៣ (ក) (Viii), (ខ) (iii), និង (គ) (iii) នៃសេចក្ដីណែនាំនេះ មិនអនុវត្តចំពោះអតិថិជន ដែលជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតដែលបានចុះបញ្ជីនោះទេ។

ង- បុគ្គលរាយការណ៍ត្រូវស្វែងរក ឬស្រាវជ្រាវជាមូលដ្ឋាន អំពីសាវតាររបស់អតិថិជននោះ ដើម្បីធានាថានីតិបុគ្គលនេះ មិនត្រូវបានកំណត់ឱ្យរំលាយ ឬបញ្ចប់សកម្មភាព ឬមិនស្ថិតក្នុងដំណើរការរំលាយ ឬបញ្ចប់សកម្មភាពនោះទេ។

ច- បុគ្គលរាយការណ៍ត្រូវផ្ទៀងផ្ទាត់អត្តសញ្ញាណរបស់ហត្ថលេខីទាំងអស់នៃគណនី ដោយយោងទៅតាមវិធានការយកចិត្តទុកដាក់ស្គាល់អតិថិជនដែលជារូបវន្តបុគ្គល។ បុគ្គលរាយការណ៍ត្រូវយកចិត្តទុកដាក់នៅពេលមានការផ្លាស់ប្ដូរហត្ថលេខី ដើម្បីធានាថាអត្តសញ្ញាណរបស់ហត្ថលេខីថ្មីទាំងអស់ត្រូវបានផ្ទៀងផ្ទាត់។

ឆ- ដើម្បីផ្ទៀងផ្ទាត់ព័ត៌មានដែលទទួលបាន បុគ្គលរាយការណ៍ត្រូវពិនិត្យជាមួយបញ្ជីរបស់អតិថិជនអំពីភាពត្រឹមត្រូវនៃព័ត៌មានដែលបានផ្ដល់ឱ្យ អំពីអត្តសញ្ញាណរបស់អតិថិជន និងនាយក ដៃគូអាជីវកម្ម ភាគទុនិក និងបុគ្គលដែលទទួលសិទ្ធិជាអ្នកតំណាង ឬអត្ថគាហកចុងក្រោយរបស់នីតិបុគ្គល។

៤.២.៤ អតិថិជនជា ឬតំណាងឱ្យបរធនបាលកិច្ច ក្រុមហ៊ុនអាណត្តិព្យាបាល ឬ កិច្ចសម្របសម្រួលផ្លូវច្បាប់

ក- នៅពេលអនុវត្តវិធានការយកចិត្តទុកដាក់ស្គាល់អតិថិជនជា ឬតំណាងឱ្យបរធនបាលកិច្ច ឬក្រុមហ៊ុនអាណត្តិព្យាបាល ឬកិច្ចសម្របសម្រួលផ្លូវច្បាប់ បុគ្គលរាយការណ៍ត្រូវប្រមូលព័ត៌មានពីអតិថិជនយ៉ាងតិច ដូចខាងក្រោម៖

i. ឈ្មោះរបស់បរធនបាលកិច្ច ឬក្រុមហ៊ុនអាណត្តិព្យាបាល ឬកិច្ចសម្របសម្រួលផ្លូវច្បាប់

ii. ឈ្មោះរបស់បុគ្គលដែលត្រូវបានផ្ដល់សិទ្ធិឱ្យកាន់កាប់ ឬចាត់ចែងលើទ្រព្យសម្បត្តិរបស់បរធនបាលកិច្ច ឬក្រុមហ៊ុនអាណត្តិព្យាបាល ឬកិច្ចសម្របសម្រួលផ្លូវច្បាប់ (បរធនបាល ឬអ្នកទទួលអាណត្តិព្យាបាល)

iii. ឈ្មោះរបស់បុគ្គលដែលបានផ្ដល់ ឬបរិច្ចាគទ្រព្យសម្បត្តិដែលបានកាន់កាប់ជំនួសឱ្យបរធនបាលកិច្ច ឬក្រុមហ៊ុនអាណត្តិព្យាបាល ឬកិច្ចសម្របសម្រួលផ្លូវច្បាប់ (បរធនបាលទាយក អ្នកផ្ដល់ជំនួយ ឬអ្នកប្រគល់អាណត្តិព្យាបាល)

iv. ឈ្មោះរបស់អ្នកតែងតាំងដែលបានតែងតាំងបុគ្គលនោះ

v. ឈ្មោះរបស់បុគ្គលម្នាក់ ឬបុគ្គលច្រើននាក់ ឬក្រុមបុគ្គលដែលទទួលប្រយោជន៍ពីបរធនបាលកិច្ច ឬក្រុមហ៊ុនអាណត្តិព្យាបាល ឬកិច្ចសម្របសម្រួលផ្លូវច្បាប់ ដែលត្រូវបានបង្កើតឡើង (អត្ថគាហក)

ខ- ព័ត៌មានដូចមានចែងក្នុងចំណុច ៤.២.៤ (ក) នៅក្នុងសេចក្ដីណែនាំនេះ ត្រូវផ្ទៀងផ្ទាត់ ជាមួយឯកសារច្បាប់ដើម និងថតចម្លងទុកនូវឯកសារ ដូចខាងក្រោម៖

i. ឯកសារសម្គាល់ឬឯកសារផ្សេងទៀត ដែលបង្កើតបរធនបាលកិច្ច ឬក្រុមហ៊ុនអាណត្តិព្យាបាល ឬកិច្ចសម្របសម្រួលផ្លូវច្បាប់

ii. ឯកសារសម្គាល់ឬឯកសារផ្សេងទៀត ដែលតែងតាំងឬកំណត់អត្តសញ្ញាណបុគ្គល ដែលមានចែងនៅក្នុងចំណុច ៤.២.៤ (ក)(ii-v) នៃសេចក្ដីណែនាំនេះ ឬបុគ្គលផ្សេងទៀតណាម្នាក់ដែលពាក់ព័ន្ធនឹងប្រតិបត្តិការរបស់បរធនបាលកិច្ច ឬក្រុមហ៊ុនអាណត្តិព្យាបាល ឬកិច្ចសម្របសម្រួលផ្លូវច្បាប់

គ- បុគ្គលរាយការណ៍ត្រូវទាមទារការធានាជាលាយលក្ខណ៍អក្សរពីបុគ្គលដែលត្រូវបានផ្ដល់សិទ្ធិកាន់កាប់ ឬចាត់ចែងលើទ្រព្យសម្បត្តិរបស់បរធនបាលកិច្ច ឬក្រុមហ៊ុនអាណត្តិព្យាបាល ឬកិច្ចសម្របសម្រួលផ្លូវច្បាប់ (បរធនបាល) ដើម្បីប្រមូល កត់ត្រា រក្សាទុកភ័ស្តុតាង អត្តសញ្ញាណរបស់អត្ថគាហក និងដើម្បីធានាថាបរធនបាលកិច្ច ឬក្រុមហ៊ុនអាណត្តិព្យាបាល ឬកិច្ចសម្របសម្រួលផ្លូវច្បាប់ ឬអ្នកទទួលបរធនបាលកិច្ចនោះមានព័ត៌មានពេញលេញពីប្រភពមូលនិធិនិងទ្រព្យធន។ ការធានានេះរួមជាមួយនឹងព័ត៌មានអំពីអត្តសញ្ញាណណាមួយ ត្រូវផ្ដល់ឱ្យបុគ្គលរាយការណ៍ភ្លាមនៅពេលមានសំណើសុំ។

៤.២.៥ តម្រូវការផ្សេងទៀតទាក់ទងនឹងការកំណត់អត្តសញ្ញាណ និងការផ្ទៀងផ្ទាត់អត្តសញ្ញាណអតិថិជនដែលជានីតិបុគ្គល ឬដែលជា ឬជាតំណាងបរធនបាលកិច្ច ឬក្រុមហ៊ុនអាណត្តិព្យាបាល ឬកិច្ចសម្របសម្រួលផ្លូវច្បាប់

នៅពេលបុគ្គលរាយការណ៍កំពុងដំណើរការបង្កើតទំនាក់ទំនងអាជីវកម្មជាមួយនីតិបុគ្គល ឬបុគ្គលដែលតំណាងឱ្យបរធនបាលកិច្ច ឬក្រុមហ៊ុនអាណត្តិព្យាបាល ឬកិច្ចសម្របសម្រួលផ្លូវច្បាប់ បុគ្គលរាយការណ៍ត្រូវចាត់វិធានការសមស្របដើម្បីយល់ដឹងពីរចនាសម្ព័ន្ធ និងអត្ថគាហកចុងក្រោយរបស់នីតិបុគ្គល និងទ្រព្យសម្បត្តិដែលត្រូវបានកាន់កាប់ជំនួសឱ្យបរធនបាលកិច្ច ឬក្រុមហ៊ុនអាណត្តិព្យាបាល ឬកិច្ចសម្របសម្រួលផ្លូវច្បាប់។

៤.២.៦ អតិថិជនដែលជាអង្គការមិនមែនរដ្ឋាភិបាល ឬអង្គការមូលនិធិ

ក- បុគ្គលរាយការណ៍ត្រូវតែតម្រូវឱ្យអង្គការមិនមែនរដ្ឋាភិបាល ឬអង្គការមូលនិធិដែលបង្កើតទំនាក់ទំនងអាជីវកម្មផ្ដល់ឯកសារស្ដីពីការបង្កើត ឬឯកសារស្រដៀងគ្នាផ្សេងទៀត ដើម្បីធានាថាអង្គការនោះត្រូវបានបង្កើតឡើង និងចុះឈ្មោះបានត្រឹមត្រូវ។

ខ- បុគ្គលរាយការណ៍ត្រូវផ្ទៀងផ្ទាត់រាល់អត្តសញ្ញាណរបស់ហត្ថលេខីទាំងអស់នៃគណនី ដោយយោងទៅតាមវិធានការយកចិត្តទុកដាក់ស្គាល់អតិថិជនដែលជារូបវន្តបុគ្គល ស្របតាមតម្រូវការនៃចំណុច ៤.២.២ នៃសេចក្ដីណែនាំនេះ។ បុគ្គលរាយការណ៍ត្រូវយកចិត្តទុកដាក់នៅពេលមានការផ្លាស់ប្ដូរហត្ថលេខី ដើម្បីធានាថាអត្តសញ្ញាណរបស់ហត្ថលេខីទាំងអស់ត្រូវបានផ្ទៀងផ្ទាត់។

គ- បុគ្គលរាយការណ៍ត្រូវចាត់វិធានការ ដើម្បីយល់ដឹងអំពីបុគ្គលដែលជាអ្នកគ្រប់គ្រង និងជាអ្នកសម្រេចចិត្ត ពាក់ព័ន្ធនឹងអង្គការមិនមែនរដ្ឋាភិបាល ឬអង្គការមូលនិធិ និងការប្រើប្រាស់មូលនិធិ។

## ៤.៣ អត្ថគាហកចុងក្រោយ

បុគ្គលរាយការណ៍ត្រូវអនុវត្តវិធានការយកចិត្តទុកដាក់ស្គាល់អតិថិជនបន្ថែមរហូតទាល់តែកំណត់បានអត្តសញ្ញាណរបស់រូបវន្តបុគ្គល ដែលជាអត្ថគាហកចុងក្រោយ ស្របតាមតម្រូវការក្នុងកថាខណ្ឌទី៥ (ខ) នៃមាត្រា៨ នៃច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ប្រសិនបើបន្ទាប់ពីបញ្ចប់ការកំណត់អត្តសញ្ញាណ និងផ្ទៀងផ្ទាត់ ដែលមានចែងក្នុងចំណុច ៤.២.២ ដល់ ចំណុច ៤.២.៦ នៃសេចក្តីណែនាំនេះ បុគ្គលរាយការណ៍នៅតែមិនប្រាកដក្នុងចិត្តថា៖

ក- អតិថិជនគឺជានីតិបុគ្គល និងជាអត្ថគាហកចុងក្រោយរបស់អតិថិជន ឬ

ខ- អតិថិជនគឺជាម្ចាស់កម្មសិទ្ធិស្របច្បាប់ និងជាអត្ថគាហកចុងក្រោយនៃទ្រព្យសម្បត្តិ ដែលជាកម្មវត្ថុនៃប្រតិបត្តិការ ឬប្រតិបត្តិការដែលគ្រោងនឹងធ្វើជាមួយអតិថិជននេះ។

## ៤.៤ បុគ្គលពាក់ព័ន្ធនយោបាយ

៤.៤.១ ពាក់ព័ន្ធនឹងបុគ្គលពាក់ព័ន្ធនយោបាយបរទេស បុគ្គលរាយការណ៍ត្រូវអនុវត្តវិធានការយកចិត្តទុកដាក់ស្គាល់អតិថិជនដូចមានចែងនៅក្នុងច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងចំណុច ៤.៣ នៃសេចក្តីណែនាំនេះ និងលើសពីនេះ បុគ្គលរាយការណ៍ត្រូវ៖

ក- ទទួលការអនុម័តពីគណៈគ្រប់គ្រងជាន់ខ្ពស់មុនពេលបង្កើតទំនាក់ទំនងជាមួយ (ឬបន្តទំនាក់ទំនងអាជីវកម្មសម្រាប់អតិថិជនដែលមានស្រាប់)

ខ- ចាត់វិធានការសមស្របដើម្បីកំណត់លើប្រភពមូលនិធិ និងទ្រព្យធនរបស់បុគ្គលពាក់ព័ន្ធនយោបាយបរទេស និងអត្ថគាហកចុងក្រោយដែលជាបុគ្គលពាក់ព័ន្ធនយោបាយ

គ- ធានាថាការពង្រឹងការតាមដាន ការតាមដានជាប្រចាំត្រូវបានអនុវត្តចំពោះទំនាក់ទំនងនោះ និង

ឃ- ដាក់ឱ្យប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងហានិភ័យ ដើម្បីកំណត់អត្តសញ្ញាណអតិថិជន ឬអត្ថគាហកចុងក្រោយដែលជាបុគ្គលពាក់ព័ន្ធនយោបាយបរទេស។

៤.៤.២ ចំពោះបុគ្គលពាក់ព័ន្ធនយោបាយក្នុងស្រុក ឬបុគ្គលពាក់ព័ន្ធនយោបាយអន្តរជាតិ បុគ្គលរាយការណ៍ត្រូវអនុវត្តវិធានការយកចិត្តទុកដាក់ស្គាល់អតិថិជនដែលមានចែងនៅក្នុងច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងចំណុច ៤.៣ នៃសេចក្តីណែនាំនេះ និងលើសពីនេះ បុគ្គលរាយការណ៍ត្រូវ៖

ក- ចាត់វិធានការសមស្របដើម្បីកំណត់ថាតើអតិថិជន ឬអត្ថគាហកចុងក្រោយគឺជាបុគ្គលពាក់ព័ន្ធនយោបាយក្នុងស្រុក ឬបុគ្គលពាក់ព័ន្ធនយោបាយអន្តរជាតិ និង

ខ- អនុវត្តការពង្រឹងការតាមដាន ការតាមដានជាប្រចាំនៅពេលដែលអតិថិជនត្រូវបានចាត់ទុកថាជាបុគ្គលពាក់ព័ន្ធនយោបាយក្នុងស្រុក ឬបុគ្គលពាក់ព័ន្ធនយោបាយអន្តរជាតិ និងទំនាក់ទំនងនេះត្រូវបានវាយតម្លៃថាមានហានិភ័យខ្ពស់។

៤.៤.៣ វិធានការដូចមានចែងក្នុងចំណុច ៤.៤.១ និងចំណុច ៤.៤.២ នៃសេចក្តីណែនាំនេះ ត្រូវអនុវត្តផងដែរចំពោះសមាជិកគ្រួសារ និងសមាគតជិតស្និទ្ធរបស់បុគ្គលពាក់ព័ន្ធនយោបាយទាំងអស់។

## ៤.៥ ការពឹងផ្អែកលើអន្តរការី ឬភាគីទីបីសម្រាប់វិធានការយកចិត្តទុកដាក់ស្គាល់អតិថិជន ឬអាជីវកម្ម

៤.៥.១ បុគ្គលរាយការណ៍អាចពឹងផ្អែកលើភាគីទីបី ដើម្បីអនុវត្តវិធានការយកចិត្តទុកដាក់ស្គាល់អតិថិជនពាក់ព័ន្ធនឹងការកំណត់អត្តសញ្ញាណអតិថិជន ឬអត្ថគាហកចុងក្រោយ ឬម្ចាស់កម្មសិទ្ធិ និងរចនាសម្ព័ន្ធគ្រប់គ្រងរបស់អតិថិជន និងការទទួលបានព័ត៌មានដើម្បីយល់ដឹងលើចរិតលក្ខណៈ និងគោលបំណងនៃទំនាក់ទំនងរបស់អាជីវកម្មនោះ។ យ៉ាងហោចណាស់វិធានការនេះត្រូវស្របតាមតម្រូវការនៃមាត្រា៨ នៃច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងសេចក្តីណែនាំនេះ។ បុគ្គលរាយការណ៍នៅតែទទួលខុសត្រូវចុងក្រោយចំពោះវិធានការយកចិត្តទុកដាក់ស្គាល់អតិថិជននេះ។

៤.៥.២ បុគ្គលរាយការណ៍ត្រូវធានាថា ភាគីទីបីដែលបានពឹងផ្អែកលើការអនុវត្តវិធានការយកចិត្តទុកដាក់ស្គាល់អតិថិជនដូចមានចែងនៅចំណុច ៤.៥.១ នៃសេចក្តីណែនាំនេះ បានរក្សាទុកក្នុងកំណត់ត្រារបស់ខ្លួននូវទិន្នន័យអត្តសញ្ញាណ និងឯកសារពាក់ព័ន្ធដទៃទៀត ដែលជាផ្នែកមួយនៃដំណើរការយកចិត្តទុកដាក់ស្គាល់អតិថិជន នៅពេលមានការតម្រូវ បុគ្គលរាយការណ៍អាចប្រើប្រាស់កំណត់ត្រានោះភ្លាមដោយគ្មានបង្អង់។

៤.៥.៣ បុគ្គលរាយការណ៍ត្រូវប្រាកដថា ភាគីទីបីដែលបានពឹងផ្អែកលើការអនុវត្តវិធានការយកចិត្តទុកដាក់ស្គាល់អតិថិជន ត្រូវស្ថិតនៅក្រោមការគ្រប់គ្រង ឬការត្រួតពិនិត្យ ឬការតាមដានអំពីការប្រតិបត្តិតាមស្តង់ដាររបស់ក្រុមការងារហិរញ្ញវត្ថុ (Financial Action Task Force - FATF) ពាក់ព័ន្ធនឹងវិធានការយកចិត្តទុកដាក់ស្គាល់អតិថិជន និងការរក្សាទុកកំណត់ត្រា នៅក្នុងយុត្តាធិការផ្សេងទៀត។

៤.៥.៤ បុគ្គលរាយការណ៍មិនត្រូវអនុញ្ញាតឱ្យភាគីទីបីអនុវត្តវិធានការយកចិត្តទុកដាក់ស្គាល់អតិថិជន ប្រសិនបើពួកគេស្ថិតនៅក្នុងយុត្តាធិការ ដែលត្រូវបានកំណត់ថាមានហានិភ័យសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មកម្រិតខ្ពស់ ស្របតាមការកំណត់នៅក្នុងសេចក្តីណែនាំរបស់អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា។

៤.៥.៥ បុគ្គលរាយការណ៍អាចពឹងផ្អែកលើភាគីទីបី ដើម្បីអនុវត្តវិធានការយកចិត្តទុកដាក់ស្គាល់អតិថិជន ដូចមានចែងក្នុងចំណុច ៤.៥.១ នៃសេចក្តីណែនាំនេះ ប្រសិនបើភាគីទីបីនោះស្ថិតក្នុងក្រុមហិរញ្ញវត្ថុដូចគ្នាជាមួយនឹងបុគ្គលរាយការណ៍ និង៖

ក- ក្រុមហិរញ្ញវត្ថុដែលអនុវត្តវិធានការយកចិត្តទុកដាក់ស្គាល់អតិថិជន និងការរក្សាទុកកំណត់ត្រា ស្របតាមការតម្រូវនៃច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងសេចក្តីណែនាំនេះ

ខ- ការអនុវត្តវិធានការយកចិត្តទុកដាក់ស្គាល់អតិថិជន និងការរក្សាទុកកំណត់ត្រារបស់ក្រុមហិរញ្ញវត្ថុ ត្រូវបានត្រួតពិនិត្យនៅកម្រិតក្រុមហិរញ្ញវត្ថុ ដោយអាជ្ញាធរមានសមត្ថកិច្ចមួយ និង

គ- ដំណើរការអនុវត្តវិធានការយកចិត្តទុកដាក់ស្គាល់អតិថិជន ដែលបានអនុវត្តនៅក្នុងប្រទេសដែលមានហានិភ័យខ្ពស់ វិធានការសមស្របក្នុងការកាត់បន្ថយហានិភ័យ ដែលកំណត់ដោយគោលនយោបាយស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុង របស់ក្រុមហិរញ្ញវត្ថុ

៤.៥.៦ បុគ្គលរាយការណ៍ត្រូវពិនិត្យឡើងវិញជាទៀងទាត់នូវវិធានការយកចិត្តទុកដាក់ស្គាល់អតិថិជនដែលអនុវត្តដោយភាគីទីបី។

## ៤.៦ វិធានការសាមញ្ញនៃការយកចិត្តទុកដាក់ស្គាល់អតិថិជន

៤.៦.១ នៅពេលបុគ្គលរាយការណ៍បានវាយតម្លៃហានិភ័យជាលាយលក្ខណ៍អក្សរដែលបង្ហាញថាផលិតផលនិងសេវាកម្ម ភូមិសាស្ត្រ ប្រតិបត្តិការ បណ្តាញចែកចាយ និង/ឬបច្ចេកវិទ្យា ឬក្រុមអតិថិជនមានហានិភ័យសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មទាប បុគ្គលរាយការណ៍អាចអនុវត្តវិធានការសាមញ្ញនៃការយកចិត្តទុកដាក់ស្គាល់អតិថិជន ដែលមានលក្ខណៈធូរស្រាលជាងវិធានការយកចិត្តទុកដាក់ស្គាល់អតិថិជន ពាក់ព័ន្ធនឹងផលិតផល បណ្តាញចែកចាយ និង/ឬបច្ចេកវិទ្យា ឬក្រុមអតិថិជនទាំងនោះ។

៤.៦.២ វិធានការសាមញ្ញនៃការយកចិត្តទុកដាក់ស្គាល់អតិថិជនដែលអនុវត្តដោយបុគ្គលរាយការណ៍ត្រូវ៖

ក- សមាមាត្រជាមួយហានិភ័យសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ដែលបានកំណត់នៅក្នុងការវាយតម្លៃហានិភ័យ

ខ- ចែងជាលាយលក្ខណ៍អក្សរឱ្យច្បាស់លាស់នៅក្នុងនីតិវិធី គោលការណ៍ណែនាំ និងក្បួនស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មរបស់បុគ្គលរាយការណ៍។

៤.៦.៣ ចាប់តាំងពីកាលបរិច្ឆេទនៃការចាប់ផ្តើមអនុវត្តដែលមានចែងនៅក្នុងចំណុច ៤.៦.១ នៃសេចក្តីណែនាំនេះ បុគ្គលរាយការណ៍មិនត្រូវអនុវត្តវិធានការសាមញ្ញនៃការយកចិត្តទុកដាក់ស្គាល់អតិថិជន នៅពេលមានការសង្ស័យពីការសម្អាតប្រាក់ ឬហិរញ្ញប្បទានភេរវកម្ម ឬនៅពេលដែលសេណារីយ៉ូមានហានិភ័យខ្ពស់កើតឡើង។

## ៤.៧ វិធានការបន្ថឹងការយកចិត្តទុកដាក់ស្គាល់អតិថិជន

៤.៧.១ បុគ្គលរាយការណ៍ត្រូវអនុវត្តវិធានការបន្ថឹងការយកចិត្តទុកដាក់ស្គាល់អតិថិជនចំពោះអតិថិជនដែលមានហានិភ័យខ្ពស់គ្រប់ប្រភេទ រួមទាំងអតិថិជនជាបុគ្គលពាក់ព័ន្ធនយោបាយបរទេស និងប្រភេទហានិភ័យផ្សេងទៀតរួមមាន ហានិភ័យទីតាំងភូមិសាស្ត្រ ឬហានិភ័យដែលពាក់ព័ន្ធនឹងផលិតផលនិងសេវាកម្ម បណ្តាញចែកចាយ និង/ឬបច្ចេកវិទ្យា មានកម្រិតខ្ពស់ ដើម្បីធានាថាបុគ្គលរាយការណ៍មិនត្រូវបានបំភាន់ដោយអ្នកសម្អាតប្រាក់ និងអ្នកផ្តល់ហិរញ្ញប្បទានភេរវកម្ម។

៤.៧.២ កត្តាហានិភ័យទាំងអស់ រួមមាន៖ ហានិភ័យទីតាំងភូមិសាស្ត្រនិងប្រទេស ហានិភ័យផលិតផលនិងសេវាកម្ម និងហានិភ័យពាក់ព័ន្ធនឹងប្រភេទប្រតិបត្តិការ បណ្តាញចែកចាយ និង/ឬបច្ចេកវិទ្យាដូចជា អាជីវកម្មប្តូរប្រាក់ ទំនាក់ទំនងអាជីវកម្មមិនជួបផ្ទាល់ សេវាកម្មធនាគារឯកជនជាដើម ត្រូវបានបញ្ចូល ដើម្បីកំណត់ថាតើអតិថិជន ឬប្រតិបត្តិការណាដែលមានហានិភ័យសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មកម្រិតខ្ពស់។

៤.៧.៣ វិធានការបន្ថឹងការយកចិត្តទុកដាក់ស្គាល់អតិថិជនយ៉ាងហោចត្រូវ៖

ក- ប្រមូលព័ត៌មានលម្អិតបន្ថែមពីអតិថិជន ជាពិសេស គោលបំណង ចរិតលក្ខណៈ និងមូលហេតុនៃទំនាក់ទំនងអាជីវកម្ម និងប្រភពមូលនិធិនិងមូលធន។

ខ- ធ្វើសវនកម្មឱ្យបានញឹកញាប់ និងពិនិត្យលើសកម្មភាពរបស់អតិថិជន ដោយមន្ត្រីប្រតិបត្តិ និងសវនករ

គ- ស្រាវជ្រាវដោយឯករាជ្យ និងស្វែងរកប្រភពព័ត៌មានបន្ថែមអំពីអតិថិជន

ឃ- ទទួលបានការអនុម័តពីគណៈគ្រប់គ្រងជាន់ខ្ពស់ ដើម្បីចាប់ផ្តើម ឬបន្តទំនាក់ទំនងអាជីវកម្ម និង

ង- អនុវត្តយន្តការតាមដាននិងរាយការណ៍ ដើម្បីកំណត់សកម្មភាពសម្អាតប្រាក់ ឬហិរញ្ញប្បទានភេរវកម្មដែលនឹងអាចកើតមាន។

## ៤.៨ ការយកចិត្តទុកដាក់ស្គាល់អតិថិជនជាប្រចាំ

៤.៨.១ បុគ្គលរាយការណ៍ត្រូវអនុវត្តការយកចិត្តទុកដាក់ស្គាល់អតិថិជននិងការពិនិត្យពិច័យជាប្រចាំ ដើម្បីធានាថាព័ត៌មានដែលទទួលបាន មានបច្ចុប្បន្នភាពនិងគ្រប់គ្រាន់ពេញលេញ និងធានាថាប្រតិបត្តិការដែលបានធ្វើឡើង ស្របតាមកម្រិតនៃការយល់ដឹងរបស់បុគ្គលរាយការណ៍ពីអតិថិជន អាជីវកម្ម រចនាសម្ព័ន្ធនៃកម្មសិទ្ធិនិងការគ្រប់គ្រង និងសារៈតារហានិភ័យរបស់អតិថិជននោះ និងប្រសិនបើចាំបាច់ ត្រូវយល់ដឹងពីប្រភពមូលនិធិនិងមូលធន។

៤.៨.២ ការបដិសេធរបស់អតិថិជនក្នុងការផ្តល់ព័ត៌មានក្នុងអំឡុងពេលអនុវត្តនីតិវិធីនៃការយកចិត្តទុកដាក់ស្គាល់អតិថិជនជាលើកដំបូង ឬជាប្រចាំ ឬមិនសហការក្នុងដំណើរការយកចិត្តទុកដាក់ស្គាល់អតិថិជនរបស់បុគ្គលរាយការណ៍ត្រូវបានចាត់ទុកថាជាការសង្ស័យ ហើយអាចរាយការណ៍ ស្របតាមមាត្រា១២ នៃច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម។

## ៤.៩ អតិថិជនមានស្រាប់

៤.៩.១ បុគ្គលរាយការណ៍ត្រូវចាត់វិធានការចាំបាច់ ដើម្បីធានាថា កំណត់ត្រារបស់អតិថិជនមានស្រាប់ត្រូវបានធ្វើបច្ចុប្បន្នកម្ម និងមានភាពគ្រប់គ្រាន់ពេញលេញ។ លើសពីនេះ បុគ្គលរាយការណ៍ត្រូវប្រមូលភស្តុតាងបន្ថែមអំពីអត្តសញ្ញាណអតិថិជនដែលមានស្រាប់ ប្រសិនបើចាំបាច់ ដើម្បីធានាការប្រតិបត្តិតាមបទដ្ឋាននៃការយកចិត្តទុកដាក់ស្គាល់អតិថិជនដូចមានចែងនៅក្នុងសេចក្តីណែនាំនេះ។

៤.៩.២ បុគ្គលរាយការណ៍ត្រូវពិនិត្យឡើងវិញជាប្រចាំលើកំណត់ត្រាដែលមានស្រាប់របស់អតិថិជន។ ការពិនិត្យឡើងវិញនេះ យ៉ាងហោចណាស់ធ្វើឡើងនៅពេល៖

ក- ប្រតិបត្តិការសំខាន់ៗកើតឡើង

ខ- មានការប្រែប្រួលជាមូលដ្ឋាននៃការពិតនៃវិធីសាស្ត្រប្រតិបត្តិការរបស់គណនី

គ- មានការប្រែប្រួលសំខាន់ៗនៃអត្តសញ្ញាណរបស់អតិថិជន ឬ

ឃ- ព័ត៌មានដែលទទួលបានពីអតិថិជនពុំគ្រប់គ្រាន់។

៤.៩.៣ ប្រសិនបើពុំមានករណីខាងលើកើតឡើង បុគ្គលរាយការណ៍ត្រូវប្រមូលព័ត៌មានបន្ថែមពីអតិថិជនមានស្រាប់ដែលមានហានិភ័យខ្ពស់ ផ្អែកលើការវាយតម្លៃហានិភ័យ និងស្របតាមបទដ្ឋានបច្ចុប្បន្នរបស់ខ្លួន។

## ៤.១០ ការធានារ៉ាប់រង

៤.១០.១ បុគ្គលរាយការណ៍ ត្រូវអនុវត្តវិធានការយកចិត្តទុកដាក់ស្គាល់អតិថិជនបន្ថែម ស្របតាមតម្រូវការនៃផ្នែកនេះបន្ថែមលើវិធានការដែលមានស្រាប់ដូចមានចែងក្នុងច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងសេចក្តីណែនាំនេះ នៅពេលផ្តើមធ្វើទំនាក់ទំនងអាជីវកម្មជាមួយអតិថិជនពាក់ព័ន្ធនឹងការធានារ៉ាប់រងអាយុជីវិត ឬទម្រង់នៃការវិនិយោគផ្សេងទៀតពាក់ព័ន្ធនឹងការធានារ៉ាប់រង។

៤.១០.២ នៅពេលកំណត់បានពីអត្តសញ្ញាណរបស់អត្ថគាហកនៃការធានារ៉ាប់រងអាយុជីវិត ឬទម្រង់នៃការវិនិយោគផ្សេងទៀតពាក់ព័ន្ធទៅនឹងការធានារ៉ាប់រង បុគ្គលរាយការណ៍ត្រូវ៖

ក- យកឈ្មោះរបស់អត្ថគាហក ប្រសិនបើអត្ថគាហក ត្រូវបានកំណត់អត្តសញ្ញាណជារូបវន្តបុគ្គល ឬនីតិបុគ្គល ឬកិច្ចសម្របសម្រួលផ្លូវច្បាប់

ខ- ត្រូវប្រមូលព័ត៌មានឱ្យបានគ្រប់គ្រាន់ពាក់ព័ន្ធនឹងអត្ថគាហក ដើម្បីអាចឱ្យបុគ្គលរាយការណ៍កំណត់អត្តសញ្ញាណនៃអត្ថគាហកនៅពេលទូទាត់សំណង ប្រសិនបើអត្ថគាហក ត្រូវបានកំណត់ដោយលក្ខខណ្ឌនានា ឬជាសមាជិករបស់ក្រុមបុគ្គលមួយ។

៤.១០.៣ ទោះបីជាការកំណត់អត្តសញ្ញាណក្នុងទម្រង់ណាមួយ ស្របតាមចំណុច ៤.១០.២ នៃសេចក្តីណែនាំនេះ បុគ្គលរាយការណ៍ត្រូវផ្ទៀងផ្ទាត់អត្តសញ្ញាណរបស់អត្ថគាហក នៅមុនពេលទូទាត់សំណងចុងក្រោយនៃការធានារ៉ាប់រងអាយុជីវិត។

៤.១០.៤ បុគ្គលរាយការណ៍ត្រូវ៖

ក- បញ្ចូលអត្ថគាហក នៃការធានារ៉ាប់រងអាយុជីវិត ឬទម្រង់នៃការវិនិយោគផ្សេងទៀតពាក់ព័ន្ធនឹងការធានារ៉ាប់រងជាកត្តាហានិភ័យពាក់ព័ន្ធ ដើម្បីកំណត់ថាតើត្រូវអនុវត្តវិធានការបន្ថែមការយកចិត្តទុកដាក់ស្គាល់អតិថិជន។ ប្រសិនបើបុគ្គលរាយការណ៍កំណត់ថាអត្ថគាហក ដែលជានីតិបុគ្គល ឬជាកិច្ចសម្របសម្រួលផ្លូវច្បាប់មានហានិភ័យខ្ពស់ បុគ្គលរាយការណ៍ត្រូវអនុវត្តវិធានការបន្ថែមការយកចិត្តទុកដាក់ស្គាល់អតិថិជន ដែលរួមមានវិធានការសមស្របណាមួយ ដើម្បីកំណត់ និងផ្ទៀងផ្ទាត់អត្តសញ្ញាណរបស់អត្ថគាហក នៅពេលទូទាត់សំណងចុងក្រោយ។

ខ- ត្រូវធានាថាតម្រូវការនៃការវាយតម្លៃហានិភ័យដូចមានចែងនៅក្នុងសេចក្តីណែនាំនេះ ត្រូវបានបញ្ចូលទៅក្នុងការអនុវត្តជាក់ស្តែង និងនីតិវិធីរបស់ខ្លួន។

## ៤.១១ ការរក្សាទុកឯកសារកត់ត្រា

៤.១១.១ បុគ្គលរាយការណ៍ត្រូវកត់ត្រាអត្តសញ្ញាណអតិថិជន និងប្រតិបត្តិការក្នុងស្រុកនិងអន្តរជាតិរបស់អតិថិជន ដែលរួមមាន កំណត់ត្រាដែលបានមកពីវិធានការយកចិត្តទុកដាក់ស្គាល់អតិថិជន កំណត់ត្រាប្រតិបត្តិការ ឯកសារនៃគណនី ឯកសារទំនាក់ទំនងអាជីវកម្ម និងលទ្ធផលនៃការវិភាគដែលធ្វើឡើងចំពោះអតិថិជន រួមបញ្ចូលទាំងឯកសារដែលទាក់ទងនឹងរបាយការណ៍ប្រតិបត្តិការសង្ស័យ យ៉ាងតិចបំផុតរយៈពេល ៥(ប្រាំ) ឆ្នាំ បន្ទាប់ពីគណនីត្រូវបានបិទ ឬបន្ទាប់ពីការបញ្ចប់ទំនាក់ទំនងនៃអាជីវកម្មជាមួយអតិថិជន ឬបន្ទាប់ពីកាលបរិច្ឆេទនៃប្រតិបត្តិការតែមួយដង ឬម្តងម្កាល។

៤.១១.២ នៅពេលអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា ជូនដំណឹងទៅបុគ្គលរាយការណ៍ថាកំណត់ត្រាដែលត្រូវរក្សាទុកឯកសារដែលស្របតាមមាត្រា១១ នៃច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ត្រូវបានស្ថិតនៅក្រោមការស៊ើបអង្កេតបន្ត ឬជាកម្មវត្ថុនៃរបាយការណ៍ប្រតិបត្តិការសង្ស័យដែលបានធ្វើ កំណត់ត្រានោះត្រូវរក្សាទុកឱ្យបាន

លើសពីរយៈពេល ដែលបានកំណត់រហូតដល់ពេលទទួលបានការជូនដំណឹងពីអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា ថាកំណត់ត្រានោះលែងមានសារប្រយោជន៍។

៤.១១.៣ ឯកសារថតចំលង និង/ឬទិន្នន័យថតចំលង ដែលទាក់ទងនឹងរបាយការណ៍ដែលបានរៀបចំ ស្របតាមមាត្រា១២ នៃច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ត្រូវរក្សាទុកក្នុងយ៉ាងតិចរយៈពេល ៥(ប្រាំ) ឆ្នាំ ដោយគិតចាប់ពីកាលបរិច្ឆេទរៀបចំឯកសារនោះ ឬរយៈពេល ៥(ប្រាំ) ឆ្នាំ ក្រោយលើការបញ្ចប់ទំនាក់ទំនងអាជីវកម្មជាមួយអតិថិជន។

៤.១១.៤ បុគ្គលរាយការណ៍ត្រូវរក្សាទុកឯកសារកត់ត្រាដូចមានចែងក្នុងចំណុច ៤.៨.១ នៃសេចក្តីណែនាំនេះ ជាច្បាប់ដើម ឬច្បាប់ចម្លង ឬជាទម្រង់អេឡិចត្រូនិក តែត្រូវបានធានាថាទម្រង់ទាំងនោះមានសុវត្ថិភាពនិងអាចយកមកប្រើប្រាស់បានតាមការស្នើសុំ និងត្រូវបានផ្តល់ដោយត្រឹមត្រូវនិងទាន់ពេលវេលា។

## ៥. ការផ្តល់ព័ត៌មាន

អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា អាចតម្រូវឱ្យបុគ្គលរាយការណ៍ផ្តល់ ឬផ្តល់បន្ថែមនូវឯកសារ ឬព័ត៌មាន ឬទិន្នន័យឱ្យបានឆាប់រហ័ស នៅពេលដែលមានតម្រូវការចាំបាច់ ក្នុងគោលបំណងអនុវត្តសេចក្តីណែនាំនេះ។

## ៦. ទណ្ឌកម្ម

បុគ្គលរាយការណ៍ណាដែលមិនគោរពតាមសេចក្តីណែនាំនេះត្រូវទទួលរងទណ្ឌកម្ម ដូចមានចែងក្នុងមាត្រា៣៦ និងមាត្រា៣៧ នៃច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម។

ទទួលបានសេចក្តីណែនាំនេះគ្រប់បុគ្គលរាយការណ៍ត្រូវអនុវត្តតាមសេចក្តីណែនាំនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ សុក្រ ១៣រោច ខែ មាឃ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែ មករា ឆ្នាំ២០២១

**អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា**

**ប្រធាន**

ស.ហ.ក

**សាយ សំអាត**

**ចម្លងជូន៖**

- ការិយាល័យទីស្តីការគណៈរដ្ឋមន្ត្រី
- គណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មនិងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ
- ក្រុមប្រឹក្សាភិបាលអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា
- ឯកសារ-កាលប្បវត្តិ

# សេចក្តីណែនាំ
# ស្តីពី
# ការកំណត់ចំនួនទឹកប្រាក់ក្នុងការអនុវត្តវិធានការ យកចិត្តទុកដាក់ស្គាល់អតិថិជនសម្រាប់កាស៊ីណូ និងគ្រឹះស្ថានល្បែងស៊ីសងផ្សេងៗ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ០២ ...៤២០...៣៥៤២...ស.ហ.ក.ណន

# សេចក្តីណែនាំ
## ស្តីពី
## ការកំណត់ចំនួនទឹកប្រាក់ក្នុងការអនុវត្តវិធានការ យកចិត្តទុកដាក់ស្គាល់អតិថិជនសម្រាប់កាស៊ីណូ និងគ្រឹះស្ថានល្បែងស៊ីសងផ្សេងៗ

អនុលោមតាមមាត្រា៨ នៃច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៦២០/០២១ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២០ អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជាដាក់ចេញនូវសេចក្តីណែនាំស្តីពីការកំណត់ចំនួនទឹកប្រាក់ក្នុងការអនុវត្តវិធានការយកចិត្តទុកដាក់ស្គាល់អតិថិជន សម្រាប់កាស៊ីណូ និងគ្រឹះស្ថានល្បែងស៊ីសងផ្សេងៗ។

ចំនួនទឹកប្រាក់ក្នុងការអនុវត្តវិធានការយកចិត្តទុកដាក់ស្គាល់អតិថិជន ឬអត្ថគាហក ដែលមានប្រតិបត្តិការជាមួយកាស៊ីណូ និងគ្រឹះស្ថានល្បែងស៊ីសងផ្សេងៗ ដូចមានចែងក្នុងកថាខណ្ឌ១៣ នៃមាត្រា៤ នៃច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម មានដូចតទៅ៖

- នៅពេលអតិថិជន ឬអត្ថគាហកអនុវត្តប្រតិបត្តិការ ដែលមានទឹកប្រាក់ស្មើ ឬលើសពី ១២.០០០.០០០ (ដប់ពីរលាន) រៀល ឬសមមូលនឹងរូបិយប័ណ្ណផ្សេងទៀត
- ប្រតិបត្តិការនេះរួមមានប្រតិបត្តិការច្រើនដងរបស់អតិថិជន ឬអត្ថគាហកម្នាក់ដែលមានចំនួនសរុបនៃប្រតិបត្តិការរួមគ្នាក្នុងរយៈពេល ២៤ ម៉ោង ដែលមានចំនួនស្មើ ឬលើសពី ១២.០០០.០០០ (ដប់ពីរលាន) រៀល ឬសមមូលនឹងរូបិយប័ណ្ណផ្សេងទៀត។

កាស៊ីណូ និងគ្រឹះស្ថានល្បែងស៊ីសងផ្សេងៗ ទាំងឡាយណាដែលមិនអនុវត្តតាមសេចក្តីណែនាំនេះ ត្រូវផ្តន្ទាទោសដូចមានចែងនៅក្នុងមាត្រា៣៦ និងមាត្រា៣៧ នៃច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម។

ទទួលបានសេចក្តីណែនាំនេះ គ្រប់កាស៊ីណូ និងគ្រឹះស្ថានល្បែងស៊ីសងផ្សេងៗ ត្រូវអនុវត្តតាមខ្លឹមសារនៃសេចក្តីណែនាំនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ អង្គារ ១០កើត ខែកត្តិក ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែវិច្ឆិកា ឆ្នាំ២០២០

**អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា**
**ប្រធាន**

ស.ហ.ក

**សាយ សំអាត**

**កន្លែងទទួល៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ធនាគារជាតិនៃកម្ពុជា
- គណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ
- ក្រុមប្រឹក្សាភិបាលអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា
- គ្រប់កាស៊ីណូ និងគ្រឹះស្ថានល្បែងស៊ីសងផ្សេងៗ
- ឯកសារ-កាលប្បវត្តិ



ប្រអប់សំបុត្រលេខ ២៥, ឡូត៍លេខ ៤៨ ផ្លូវលេខ ១០២ កែងនឹងផ្លូវលេខ ១៩ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ , ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ / ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

# សេចក្តីណែនាំ
# ស្តីពី
# ការត្រួតពិនិត្យផ្តែកលើហានិភ័យ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ ធ៦២-០២០-២៦៨ ធ.ក.ជ.ស

# សេចក្តីណែនាំ
# ស្តីពី
# ការត្រួតពិនិត្យផ្អែកលើហានិភ័យ

អនុលោមតាមច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម បានប្រកាសឱ្យប្រើដោយព្រះរាជក្រម លេខ នស/រកម/០៦២០/០២១ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២០ អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជាបានចេញសេចក្តីណែនាំស្តីពីការត្រួតពិនិត្យផ្អែកលើហានិភ័យ។

## ១. វិសាលភាព

សេចក្តីណែនាំនេះត្រូវអនុវត្តចំពោះការងារត្រួតពិនិត្យផ្អែកលើហានិភ័យ ដោយមន្ត្រីត្រួតពិនិត្យរបស់អង្គភាព-ស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា ដែលតទៅនេះហៅថា "មន្ត្រីត្រួតពិនិត្យ" ចំពោះបុគ្គលរាយការណ៍ ដូចមានចែងក្នុងមាត្រា៤ នៃច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ។

## ២. ការអនុវត្តការត្រួតពិនិត្យផ្អែកលើហានិភ័យ

២.១. មន្ត្រីត្រួតពិនិត្យត្រូវអនុវត្តការត្រួតពិនិត្យផ្អែកលើហានិភ័យ ដែលសំដៅដល់ការស្វែងរក ការកំណត់ ការវាយតម្លៃ និងការយល់ដឹងពីហានិភ័យសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មរបស់បុគ្គលរាយការណ៍នីមួយៗ និងប្រើប្រាស់វិធានការសមស្របក្នុងការទប់ស្កាត់ ការគ្រប់គ្រង និងកាត់បន្ថយហានិភ័យ ដោយផ្អែកលើមូលដ្ឋាននៃការពិត និងហានិភ័យសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម (Materiality and risk) ព្រមទាំងបន្តបង្កើនប្រសិទ្ធភាពនៃការត្រួតពិនិត្យរបស់អង្គភាព-ស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា ជាប្រចាំ។

២.២. តាមរយៈការត្រួតពិនិត្យផ្អែកលើហានិភ័យនេះ មន្ត្រីត្រួតពិនិត្យត្រូវកំណត់ បែងចែកធនធាន និងរៀបចំផែនការ និងយុទ្ធសាស្ត្រត្រួតពិនិត្យ ស្របតាមកម្រិតហានិភ័យដែលបានវាយតម្លៃ។ មន្ត្រីត្រួតពិនិត្យត្រូវតាមដាន និងធ្វើបច្ចុប្បន្នកម្មសាវតារហានិភ័យ (Risk profile) របស់បុគ្គលរាយការណ៍នីមួយៗ នៅរៀងរាល់ត្រីមាសនីមួយៗ ដើម្បីធានាថាការវាយតម្លៃហានិភ័យ ត្រូវបានធ្វើឡើងសមស្រប ចំគោលដៅ និងមានប្រសិទ្ធភាព តាមរយៈការរៀបចំយុទ្ធសាស្ត្រត្រួតពិនិត្យ ការរៀបចំផែនការត្រួតពិនិត្យដល់ទីកន្លែង ការប្រើប្រាស់មធ្យោបាយត្រួតពិនិត្យសមស្រប និងការផ្លាស់ប្តូរវដ្តចរិត វិសាលភាព ភាពញឹកញាប់ ភាពស៊ីជម្រៅ និងការយកចិត្តទុកដាក់នៃការត្រួតពិនិត្យ ជាដើម។

២.៣. មន្ត្រីត្រួតពិនិត្យត្រូវប្រើប្រាស់យ៉ាងហោចណាស់ មធ្យោបាយត្រួតពិនិត្យលើឯកសារ (Off-site tools) មធ្យោបាយត្រួតពិនិត្យដល់ទីកន្លែង (On-site tools) នៅក្នុងកិច្ចដំណើរការត្រួតពិនិត្យផ្អែកលើហានិភ័យ។



ប្រអប់សំបុត្រលេខ ២៥, ឡូត៍លេខ ៤៨ ផ្លូវលេខ ១០២ កែងនឹងផ្លូវលេខ ១៩ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ , ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ / ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

២.៤. ជាផ្នែកមួយនៃការគាំទ្រដល់ការប្រើប្រាស់មធ្យោបាយត្រួតពិនិត្យលើឯកសារ មន្ត្រីត្រួតពិនិត្យត្រូវ៖

ក- ប្រមូលឯកសារ របាយការណ៍ និងព័ត៌មានពាក់ព័ន្ធផ្សេង របស់បុគ្គលរាយការណ៍

ខ- កំណត់អំពីកម្រិតនិងការប្រែប្រួលកម្រិតហានិភ័យសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម របស់បុគ្គលរាយការណ៍នីមួយៗ ដោយប្រើប្រាស់ឧបករណ៍ត្រួតពិនិត្យផ្អែកលើហានិភ័យ ដូចមាននៅក្នុងឧបសម្ព័ន្ធ និងឧបករណ៍ត្រួតពិនិត្យផ្អែកលើហានិភ័យផ្សេងទៀត ដែលរៀបចំដោយអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា។

គ- ដាក់ចេញវិធានការកែតម្រូវ ស្របតាមលទ្ធផលនៃការត្រួតពិនិត្យ ដើម្បីគ្រប់គ្រង និងកាត់បន្ថយហានិភ័យរបស់បុគ្គលរាយការណ៍នីមួយៗ ប្រសិនបើមាន

ឃ- លើកសំណើដាក់ទណ្ឌកម្មចំពោះបុគ្គលរាយការណ៍ដែលពុំមានវិធានការសមស្របក្នុងការបង្ការ ឬកាត់បន្ថយ ឬគ្រប់គ្រងហានិភ័យ ប្រសិនបើមាន។

២.៥. នៅក្នុងកិច្ចដំណើរការត្រួតពិនិត្យដល់ទីកន្លែង មន្ត្រីត្រួតពិនិត្យត្រូវកំណត់អំពី ចរិត វិសាលភាព ភាពញឹកញាប់ ភាពស៊ីជម្រៅ ការយកចិត្តទុកដាក់ និងរយៈពេលនៃចុះត្រួតពិនិត្យដល់ទីកន្លែង ដោយផ្អែកលើ៖

ក- លទ្ធផលនៃវាយតម្លៃហានិភ័យរបស់បុគ្គលរាយការណ៍ ដែលផ្តល់ដោយឧបករណ៍ត្រួតពិនិត្យផ្អែកលើហានិភ័យរបស់អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា

ខ- លទ្ធផលនៃការវាយតម្លៃហានិភ័យសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ដែលរៀបចំដោយបុគ្គលរាយការណ៍

គ- វឌ្ឍនភាពនៃការអនុវត្តអនុសាសន៍នៅក្នុងរបាយការណ៍ត្រួតពិនិត្យដល់ទីកន្លែងនៅគ្រាមុន ប្រសិនបើមាន

ឃ- ព័ត៌មាន ឬរបាយការណ៍នានា ដែលពាក់ព័ន្ធនឹងបុគ្គលរាយការណ៍។

២.៦. តាមរយៈលទ្ធផលនៃការត្រួតពិនិត្យដល់ទីកន្លែង មន្ត្រីត្រួតពិនិត្យត្រូវ៖

ក- កំណត់អំពីសកម្មភាពកែតម្រូវរបស់បុគ្គលរាយការណ៍

ខ- លើកសំណើដាក់ទណ្ឌកម្មចំពោះបុគ្គលរាយការណ៍នៅពេលរកឃើញថា ពុំមានវិធានការសមស្របក្នុងការបង្ការ ឬកាត់បន្ថយហានិភ័យ ឬពុំអនុវត្តតាមច្បាប់និងបទប្បញ្ញត្តិ ប្រសិនបើមាន

២.៧. មន្ត្រីត្រួតពិនិត្យត្រូវបង្កើនប្រសិទ្ធភាពនៃការត្រួតពិនិត្យ តាមរយៈសហប្រតិបត្តិការជាតិ និងអន្តរជាតិ។

## ៣. ការអនុវត្ត

ទទួលបានសេចក្តីណែនាំនេះគ្រប់មន្ត្រី-បុគ្គលិកនៃអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា និងបុគ្គលរាយការណ៍ត្រូវអនុវត្តតាមសេចក្តីណែនាំនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ ពុធ ៨រោច ខែស្រាពណ៍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី១២ ខែសីហា ឆ្នាំ២០២០

**អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា**

**ប្រធាន**

**សាយ សំអាត**

**ចម្លងជូន៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- គណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ
- ក្រុមប្រឹក្សាភិបាលអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា
- ឯកសារ-កាលប្បវត្តិ

© ឆ្នាំ២០២៣
មិនអនុញ្ញាតឱ្យផលិតឡើងវិញ ឬបកប្រែសៀវភៅនេះដោយគ្មានការអនុញ្ញាតជាមុនជាលាយលក្ខណ៍អក្សរឡើយ។
ការផលិតឡើងវិញទាំងស្រុង ឬមួយផ្នែកនៃសៀវភៅនេះត្រូវស្នើសុំការអនុញ្ញាតពី៖
អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា
សារអេឡិចត្រូនិច៖ cafiu_info@nbc.gov.kh
ទូរសព្ទ៖ +855 23 427 933
គេហទំព័រ៖ cafiu.nbc.gov.kh

© 2023
No reproduction or translation of this publication may be made without prior written permission.
Applications for permission to reproduce all or part of this publication should be made to:
Cambodia Financial Intelligence Unit
Email: cafiu_info@nbc.gov.kh
Tel: +855 23 427 933
Website: cafiu.nbc.gov.kh

**អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា**

សារអេឡិចត្រូនិច៖ cafiu_info@nbc.gov.kh

ទូរស័ព្ទ៖+855 23 427 933

គេហទំព័រ៖ cafiu.nbc.gov.kh